ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានកសិកម្ម

# គោលការណ៍ណែនាំបច្ចេកទេស
# ស្តីពីការត្រួតពិនិត្យគុណភាពគ្រាប់ពូជស្រូវ
# តាមប្រព័ន្ធធានាគុណភាពពូជដំណាំ (ប.គ.ព)




រៀបចំដោយ៖ អគ្គនាយកដ្ឋានកសិកម្ម

សហការគាំទ្រ និងឧបត្ថម្ភដោយ

Australian Aid   CAVAC Innovation in Agriculture   JICA   RSPP Quality Seed, Quality Rice

បោះពុម្ពលើកទី១ ចំនួន ១០០០ ក្បាល ក្រោមជំនួយរបស់កម្មវិធីកាវ៉ាក់

ខែ ឧសភា ឆ្នាំ ២០២២

# អារម្ភកថា

**ប្រព័ន្ធធានាគុណភាពពូជដំណាំ** សរសេរអក្សរកាត់ ប.គ.ព ត្រូវបានរៀបចំដោយផ្អែកលើសៀវភៅគោលការណ៍ណែនាំមួយរបស់អង្គការស្បៀងអាហារនិងកសិកម្មនៃសហប្រជាជាតិ ដែលបានរៀបចំកាលពីឆ្នាំ ២០០៦ និងត្រូវបានយកទៅអនុវត្តប្រកបដោយជោគជ័យក្នុងបណ្តាប្រទេសមួយចំនួនដែលវិស័យសាធារណៈនៅមិនទាន់មានភាពរឹងមាំ ខ្វះខាតធនធានមនុស្សនិងហិរញ្ញវត្ថុសម្រាប់អនុវត្តប្រព័ន្ធធានាគុណភាពពូជដំណាំ ដូចជា៖ ប្រទេសហ្សំប៊ៀ តង់សានី អ៊ុយហ្គង់ដា បង់ក្លាដែស នេប៉ាល់ និងឥណ្ឌា។

ដោយមើលឃើញពីភាពងាយស្រួលក្នុងការអនុវត្ត ភាពជោគជ័យនៅបណ្តាប្រទេសខាងលើ និងកង្វះខាតមន្ត្រីជំនាញ និងមធ្យោបាយនាពេលបច្ចុប្បន្ន ទើបអគ្គនាយកដ្ឋានកសិកម្ម សម្រេចជ្រើសរើស **ប.គ.ព** ជាឧបករណ៍សម្រាប់ត្រួតពិនិត្យផលិតកម្មនិងបញ្ជាក់គុណភាពគ្រាប់ពូជស្រូវនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការរៀបចំកែសម្រួល**គោលការណ៍ណែនាំបច្ចេកទេសស្តីពីការត្រួតពិនិត្យគុណភាពគ្រាប់ពូជស្រូវតាម ប.គ.ព** ឡើងវិញឱ្យស្របនឹងលក្ខខណ្ឌនៃព្រះរាជាណាចក្រកម្ពុជា គឺទទួលបានការគាំទ្រផ្នែកបច្ចេកទេស និងថវិកាពីកម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា-អូស្ត្រាលី(CAVAC) និងគម្រោងជំរុញផលិតកម្មនិងការប្រើប្រាស់គ្រាប់ពូជស្រូវ(RSPP)។ គោលការណ៍ណែនាំនេះនឹងប្រើប្រាស់ជាគោលប្រតិបត្តិក្នុងការត្រួតពិនិត្យនិងបញ្ជាក់គុណភាពផលិតកម្ម និងអាជីវកម្មគ្រាប់ពូជស្រូវ សម្រាប់សកម្មភាពបណ្តុះបណ្តាល ការងារផ្សព្វផ្សាយ និងប្រើប្រាស់តាមស្ថានភាពជាក់ស្តែងរបស់គ្រប់ភាគីពាក់ព័ន្ធនៅក្នុងវិស័យនេះ។

គោលការណ៍ណែនាំនេះបង្ហាញនូវព័ត៌មានលម្អិតពីតួនាទី និងលក្ខខណ្ឌតម្រូវរបស់មន្ត្រីត្រួតពិនិត្យគុណភាព ដំណើការត្រួតពិនិត្យគុណភាពសម្រាប់ផលិតកម្ម និងអាជីវកម្មគ្រាប់ពូជស្រូវ ឧបករណ៍និងសម្ភារៈចាំបាច់សម្រាប់ការត្រួតពិនិត្យគុណភាព និងឯកសារពាក់ព័ន្ធមួយចំនួនដោយភ្ជាប់នូវរូបភាព ដើម្បីងាយស្រួលយល់ និងប្រតិបត្តិដោយគ្រប់ភាគីពាក់ព័ន្ធស្របតាមស្ថានភាព និងលទ្ធភាពជាក់ស្តែង។

អគ្គនាយកដ្ឋានកសិកម្មសង្ឃឹមយ៉ាងមុតមាំថា គោលការណ៍ណែនាំនេះនឹងផ្តល់នូវចំណេះដឹងថ្មីៗ បទពិសោធន៍ល្អៗ និងគោលការណ៍បច្ចេកទេសជាមូលដ្ឋានសម្រាប់មន្ត្រីត្រួតពិនិត្យគុណភាពថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ និងអ្នកផលិតគ្រាប់ពូជស្រូវ។ អគ្គនាយកដ្ឋានកសិកម្មសូមស្វាគមន៍ និងទទួលយកនូវមតិយោបល់កែលម្អទាំងឡាយពីសំណាក់គ្រប់អ្នកអាននិងអ្នកមានចំណាប់អារម្មណ៍លើគោលការណែនាំបច្ចេកទេសនេះ ដើម្បីឱ្យគោលការណ៍ណែនាំនេះកាន់តែល្អប្រសើរ មានប្រសិទ្ធភាព និងសុក្រឹតភាពថែមទៀត។

ថ្ងៃ សុក្រ ១៣ រោច ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០២២

**អគ្គនាយកដ្ឋានកសិកម្ម**

**បណ្ឌិត ឌិន ឆាយ**

# ពាក្យបំព្រួញ

| | |
|---|---|
| CA | អង្គភាពមានសមត្ថកិច្ច |
| CAVAC | កម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា-អូស្ត្រាលី (កាវ៉ាក់) |
| CS | គ្រាប់ពូជវិញ្ញាបនបត្រ |
| FS | គ្រាប់ពូជគ្រឹះ |
| GDA | អគ្គនាយកដ្ឋានកសិកម្ម |
| ISTA | សមាគមវិភាគពូជដំណាំអន្តរជាតិ |
| PDAFF | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត |
| PRD | ពូជស្រូវផ្ការំដួល |
| QDS | ប្រព័ន្ធធានាគុណភាពពូជដំណាំ (ប.គ.ព) |
| RS | គ្រាប់ពូជចុះបញ្ជី |
| RSPP | គម្រោងជំរុញផលិតកម្មនិងការប្រើប្រាស់គ្រាប់ពូជស្រូវ |
| SKO-01 | ពូជស្រូវសែនក្រអូប០១ |
| SP | អ្នកផលិតគ្រាប់ពូជ |

# មាតិកា


**១សេចក្តីផ្តើម** ........ ៥

**១គោលបំណង .១.** ........ ៦

**១ តួនាទី .២.និងភារកិច្ចរបស់មន្ត្រីត្រួតពិនិត្យគុណភាព** ........ ៦

១តួនាទីរបស់មន្ត្រីត្រួតពិនិត្យគុណភាព .២.១. ........ ៦

១ភារកិច្ចរបស់មន្ត្រីត្រួតពិនិត្យគុណភាព .២.២. ........ ៦

**២សេចក្តីសង្ខេបនៃដំណើរការត្រួតពិនិត្យគុណភាព** ........ ៩

**២គោលបំណងនៃការត្រួតពិនិត្យគុណភាព .១.** ........ ១០

**២វិធានការគ្រប់គ្រងគុណភាពគ្រាប់ពូជស្រូវ .២.** ........ ១០

**២៣.គ.ដំណើរការត្រួតពិនិត្យគុណភាពគ្រាប់ពូជស្រូវតាម ប .៣.** ........ ១២

**៣ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាល** ........ ១៤

**៣គោលបំណង និងទិដ្ឋភាពត្រួតពិនិត្យគុណភាពផលិតកម្មទីវាល .១.** ........ ១៥

៣នៅដំណាក់កាលមុនពេលចេញផ្កា ១ការត្រួតពិនិត្យគុណភាពផលិតកម្មនៅទីវាលលើកទី .១.១. ........ ១៥

៣ .១.២.ការត្រួតពិនិត្យគុណភាពផលិតកម្មនៅទីវាលលើកទី២ នៅដំណាក់កាលដាក់ម្សៅ ........ ១៥

៣ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលសម្រាប់ស្រែជំនួស ក្នុងក .១.៣.រណីចាំបាច់ ........ ១៦

**៣ផ្ទៀងផ្ទាត់ប្រភពគ្រាប់ពូជគ្រឹះ ឬគ្រាប់ពូជចុះបញ្ជី .២.** ........ ១៦

**៣លក្ខខណ្ឌតម្រូវសម្រាប់ជ្រើសរើសស្រែផលិតកម្ម .៣.** ........ ១៧

**៣ការជ្រើ .៤.សរើសផ្ទៃដីយកសំណាក** ........ ១៨

**៣ស្តង់ដារគុណភាពផលិតកម្មនៅទីវាល .៥.** ........ ២១

**៣ការកំណត់ប្រភេទពូជលាយ .៦.** ........ ២១

៣.៦នៅដំណាក់កាលមុនចេញផ្កា១ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលលើកទី .១. ........ ២១

៣នៅដំណាក់កាលដា២ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលលើកទី .៦.២.ក់ម្សៅ ........ ២២

**៣ការកំណត់ស្មៅហាមឃាត់ .៧.** ........ ២២

៣នៅដំណាក់កាលមុនចេញផ្កា១ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលលើកទី .៧.១. ........ ២៣

៣នៅដំណាក់កាលដាក់ម្សៅ២ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលលើកទី .៧.២. ........ ២៣

**៣ការកំណត់ជំងឺហាមឃាត់ .៨.** ........ ២៤

៣នៅមុនដំណាក់កាលចេញផ្កា១ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលលើកទី .៨.១. ........ ២៤

៣នៅដំណាក់កាល២ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលលើកទី .៨.២.ដាក់ម្សៅ ........ ២៤

**៣ការវិនិច្ឆ័យលើដំណាំស្រូវទទួលរងផលប៉ះពាល់ .៩.** ........ ២៥

៣ការកំណត់ដំណាំស្រូវទទួលរងផលប៉ះពាល់ .៩.១. ........ ២៥

៣ .៩.២.ការវាយតម្លៃផលប៉ះពាល់ដោយសារជំងឺហាមឃាត់ ........ ២៥

៤គ្រាប់ពូជស្រូវនៅមន្ទីរពិសោធន៍ការត្រួតពិនិត្យគុណភាព ....... ២៦
៤គំនូសបំព្រួញដំណើរការយកសំណាកគ្រាប់ពូជស្រូវ .១. ....... ២៧
៤ការយកសំណាកបឋម .២. ....... ២៧
៤ការរៀបចំសំណាកបញ្ជូន .៣. ....... ២៨
៤ការវេចខ្ចប់ និងបិទស្លាកសំណាកបញ្ជូន .៤. ....... ២៩
៤ស្តុ .៥.ង់ដារគុណភាពគ្រាប់ពូជស្រូវ ....... ២៩
៤ដំណើរការត្រួតពិនិត្យគុណភាពក្នុងមន្ទីរពិសោធន៍ .៦. ....... ៣០
៤វិភាគរូបសាស្ត្រ .៧. ....... ៣០
៤វិភ .៨.ាគប្រភេទពូជ ....... ៣១
៤វិភាគសំណើមគ្រាប់ .៩. ....... ៣១
៤វិភាគដំណុះគ្រាប់ .១០. ....... ៣២
ឧបសម្ព័ន្ធទី១ ....... ៣៤
1-A. ពាក្យស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ ....... ៣៥
1-B. គម្រូលិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ ....... ៣៨
1-C. ទម្រង់៖(ក) ផែនការផលិតកម្មគ្រាប់ពូជស្រូវប្រចាំរដូវ ....... ៣៩
1-D. ទម្រង់កំណត់ត្រាត្រួតពិនិត្យគុណភាពទីវាល ....... ៤១
1-E. ទម្រង់របាយការណ៍ត្រួតពិនិត្យគុណភាពផលិតកម្មទីវាល ....... ៤២
1-F. ទម្រង់៖(ខ) សំណើសុំត្រួតពិនិត្យគុណភាពគ្រាប់ពូជ ....... ៤៤
1-G. ទម្រង់កត់ត្រាវិភាគដំណុះ ....... ៤៥
1-H. ទម្រង់របាយការណ៍ត្រួតពិនិត្យគុណភាពគ្រាប់ពូជ ....... ៤៦
ឧបសម្ព័ន្ធទី២ ....... ៤៨
១ឧបករណ៍សម្រាប់ត្រួតពិនិត្យគុណភាពទីវាល . ....... ៤៩
២ឧបករណ៍សម្រាប់យកសំណាក . ....... ៥០
៣ឧ .បករណ៍ និងសម្ភារសម្រាប់វិភាគគុណភាពនៅមន្ទីរពិសោធន៍ ....... ៥១
ឧបសម្ព័ន្ធទី៣ ....... ៥៣

# ១. សេចក្តីផ្តើម

## ១.១. គោលបំណង

គោលការណ៍ណែនាំបច្ចេកទេសស្តីពី**ការត្រួតពិនិត្យគុណភាពគ្រាប់ពូជស្រូវតាមប្រព័ន្ធធានាគុណភាពពូជដំណាំ (ប.គ.ព)** ត្រូវបានរៀបចំឡើងក្នុងគោលបំណងប្រើប្រាស់ជាឯកសារបច្ចេកទេសសម្រាប់ការបណ្តុះបណ្តាលគ្រូបង្គោល និងបណ្តុះបណ្តាលបន្តគ្រប់ភាគីពាក់ព័ន្ធ ហើយក៏ជាឯកសារយោងដ៏សំខាន់សម្រាប់មន្ត្រីត្រួតពិនិត្យគុណភាពគ្រាប់ពូជស្រូវនៃអង្គភាពមានសមត្ថកិច្ចក្នុងការប្រតិបត្តិការ **ប.គ.ព** សម្រាប់ផលិតកម្ម និងអាជីវកម្មគ្រាប់ពូជស្រូវ។

## ១.២. តួនាទី និងភារកិច្ចរបស់មន្ត្រីត្រួតពិនិត្យគុណភាព

### ១.២.១. តួនាទីរបស់មន្ត្រីត្រួតពិនិត្យគុណភាព

តួនាទីសំខាន់របស់មន្ត្រីត្រួតពិនិត្យគុណភាពគឺចុះវាយតម្លៃគុណភាពផលិតកម្មគ្រាប់ពូជស្រូវនៅទីវាលធៀបទៅនឹងពាក្យស្នើសុំក្នុងទម្រង់ (ក) តាមគោលការណ៍បច្ចេកទេស **ប.គ.ព** ស្តង់ដារទីវាល និងការយកសំណាកគ្រាប់ពូជស្រូវសម្រាប់វិភាគគុណភាពនៅមន្ទីរពិសោធន៍។

**ចំណាំ៖** មន្ត្រីត្រួតពិនិត្យគុណភាពមិនមែនជាអ្នកវិភាគគុណភាពគ្រាប់ពូជស្រូវនៅមន្ទីរពិសោធន៍ និងមិនមែនជាមន្ត្រីបច្ចេកទេសក្នុងផលិតកម្មគ្រាប់ពូជស្រូវទេ។

### ១.២.២. ភារកិច្ចរបស់មន្ត្រីត្រួតពិនិត្យគុណភាព

<u>ក. ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាល</u>

មុនពេលត្រួតពិនិត្យគុណភាពផលិតកម្មទីវាល៖

- ពិនិត្យពាក្យស្នើសុំក្នុងទម្រង់(ក) ដែលផ្តល់ឱ្យដោយអ្នកផលិតគ្រាប់ពូជ [1] បន្ទាប់មករៀបចំបញ្ជីព័ត៌មានសំខាន់ៗសម្រាប់ដំណើការវាយតម្លៃផលិតកម្មទីវាល
- ណាត់ជួបជាមួយអ្នកផលិតគ្រាប់ពូជ ដើម្បីត្រួតពិនិត្យគុណភាពផលិតកម្មទីវាលយ៉ាងហោចណាស់២៤ម៉ោងជាមុន មុនពេលចុះត្រួតពិនិត្យស្រែផលិតកម្មគ្រាប់ពូជ
- ផ្ទៀងផ្ទាត់ព័ត៌មានសំខាន់ៗទាក់ទងនឹងប្រភេទពូជ ផ្ទៃដីដាំដុះ ទីតាំង និងកូដស្រែសម្រាប់យកសំណាក
- ជ្រើសរើសដោយចៃដន្យយ៉ាងហោចណាស់១០% នៃផ្ទៃដីផលិតកម្មគ្រាប់ពូជស្រូវសរុប តាមប្រភេទពូជនិងថ្នាក់ពូជនីមួយៗសម្រាប់ត្រួតពិនិត្យគុណភាពផលិតកម្មនៅទីវាល
- ផ្ទៀងផ្ទាត់ព័ត៌មានអំពីទីតាំងស្រែ និងកំណត់ពេលវេលាសមស្របសម្រាប់ចុះត្រួតពិនិត្យគុណភាពផលិតកម្មទីវាលជាមួយអ្នកផលិតគ្រាប់ពូជ ឬតំណាង
- ពិនិត្យរបាយការណ៍ត្រួតពិនិត្យគុណភាពផលិតកម្មទីវាលពីលើកមុនឡើងវិញក្នុងករណីត្រួតពិនិត្យ

---

[1] អ្នកផលិតគ្រាប់ពូជ សំដៅដល់បុគ្គល ក្រុម ក្រុមហ៊ុន សហគមន៍កសិកម្ម សមាគម ឬអង្គការក្រៅរដ្ឋាភិបាល ដែលមានគោលបំណងផលិត និងធ្វើធុរកិច្ចគ្រាប់ពូជស្រូវ។

គុណភាពលើកទី១បានធ្វើរួចហើយ

- ត្រៀមជាស្រេចនូវឧបករណ៍និងសម្ភារចំបាច់ដូចជា ឯកសណ្ឋានការពារថ្នាំកសិកម្ម មធ្យោបាយធ្វើដំណើរ ឧបករណ៍វាស់សំណាក និងទម្រង់របាយការណ៍ត្រួតពិនិត្យគុណភាពផលិតកម្មទីវាល។

អំឡុងពេលត្រួតពិនិត្យគុណភាពផលិតកម្មទីវាល៖

- ត្រូវពិនិត្យនិងសាកសួររាល់ព័ត៌មានសំខាន់ៗពីអ្នកផលិតគ្រាប់ពូជឬតំណាងទាក់ទងនឹងព្រំប្រទល់ស្រែ ប្រភេទពូជ ប្រភពគ្រាប់ពូជ ថ្នាក់គ្រាប់ពូជ ផ្ទៃដីដាំដុះ និងប្រវត្តិដាំដុះនៃស្រែ
- ត្រួតពិនិត្យស្រែផលិតកម្មដោយអនុវត្តតាមវិធីសាស្ត្រយកសំណាកតាម **ប.គ.៣**
- វាយតម្លៃប្រភេទពូជផ្សេង(**ពូជលាយ**) ស្មៅហាមឃាត់ កម្រិតបំផ្លាញដោយជំងឺហាមឃាត់ ស្ថានភាពទូទៅនៃស្រែផលិតកម្ម ការអនុវត្តជាក់ស្តែងនៅស្រែផលិតកម្ម និងការប៉ាន់ស្មានទិន្នផលដែលអាចទទួលបាន។ **សម្គាល់៖** ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលលើកទី១ និងលើកទី២ត្រូវតែអនុវត្តក្នុងស្រែដដែល លើកលែងតែស្រែដែលបានត្រួតពិនិត្យគុណភាពផលិតកម្មរួចហើយជួបប្រទះប្រធានស័ក្តដូចជា ខូចខាតដោយគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត ការបំផ្លាញដោយសត្វល្អិតឬជំងឺបំផ្លាញធ្ងន់ធ្ងរ។ល។
- ផ្តល់អនុសាសន៍ជូនអ្នកផលិតគ្រាប់ពូជសម្រាប់សកម្មភាពកែលម្អប្រសិនបើចាំបាច់ ហើយត្រូវបញ្ចូលអនុសាសន៍ទាំងនោះទៅក្នុងរបាយណ៍ត្រួតពិនិត្យគុណភាពផលិតកម្មទីវាល។
- បំពេញរបាយការណ៍ត្រួតពិនិត្យគុណភាពផលិតកម្មទីវាលដោយមានចុះហត្ថលេខារបស់អ្នកផលិតគ្រាប់ពូជឬតំណាង និងរក្សាទុក១(មួយ)ច្បាប់សម្រាប់អ្នកផលិតកម្មគ្រាប់ពូជ ១(មួយ)ច្បាប់សម្រាប់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត និង១(មួយ)ច្បាប់ទៀតសម្រាប់នាយកដ្ឋានពូជដំណាំនៃអគ្គនាយកដ្ឋានកសិកម្ម។

ក្រោយពេលត្រួតពិនិត្យគុណភាពផលិតកម្មទីវាល៖

- ជូនដំណឹងអ្នកផលិតគ្រាប់ពូជអំពីការបដិសេធស្រែផលិតកម្មគ្រាប់ពូជ ប្រសិនបើស្រែផលិតកម្មនោះមានគុណភាពក្រោមស្តង់ដារទីវាលធ្ងន់ធ្ងរ។

### *ខ. ការត្រួតពិនិត្យគុណភាពគ្រាប់ពូជ*

មុនពេលត្រួតពិនិត្យគុណភាពគ្រាប់ពូជ៖

- ពិនិត្យពាក្យស្នើសុំក្នុងទម្រង់(ខ) និងណាត់ជួបជាមួយអ្នកផលិតគ្រាប់ពូជយ៉ាងហោចណាស់ ២៤ម៉ោងមុនពេលចុះត្រួតពិនិត្យគុណភាព
- ផ្ទៀងផ្ទាត់ទម្រង់(ខ) ដើម្បីប្រាកដអំពីទីតាំងឃ្លាំង បរិមាណគ្រាប់ពូជ ប្រភេទពូជ ថ្នាក់គ្រាប់ពូជ

និងចំនួនឡូត៍គ្រាប់ពូជដែលត្រូវត្រួតពិនិត្យ

- កំណត់ឡូត៍គ្រាប់ពូជសម្រាប់យកសំណាក បន្ទាប់ពីទទួលបានបញ្ជីឡូត៍គ្រាប់ពូជពីអ្នកផលិតគ្រាប់ពូជ
- ត្រៀមជាស្រេចនូវមធ្យោបាយធ្វើដំណើរ និងឧបករណ៍ត្រួតពិនិត្យគុណភាពគ្រាប់ពូជ ដូចជា ដែកឆាំ គ្រាប់ពូជ ជញ្ជីងថ្លឹង ថាសដាក់គ្រាប់ពូជ ក្រដាសស្អីកគ័របិទ ថង់ប្លាស្ទិច ហ្វឺតសរសេរ ម៉ាស់ពាក់ការពារ ស្រោមដៃ និងវ៉ែនតាការពារភ្នែក។

អំឡុងពេលត្រួតពិនិត្យគុណភាពគ្រាប់ពូជ៖

- យកសំណាកដោយចៃដន្យ ដោយអនុលោមទៅតាមវិធានរបស់អ៊ីសតា (ISTA)
- បិទស្លាកសម្គាល់គ្រាប់ពូជដែលបានយកសំណាកឱ្យបានត្រឹមត្រូវសម្រាប់ការវិភាគគុណភាព
- វិភាគគុណភាពគ្រាប់ពូជនៅមន្ទីរពិសោធន៍។

ក្រោយពេលត្រួតពិនិត្យគុណភាពគ្រាប់ពូជ៖

- សរសេររបាយការណ៍លទ្ធផលនៃការវិភាគ រួចបញ្ជូនទៅនាយកដ្ឋានពូជដំណាំនៃអគ្គនាយកដ្ឋានកសិកម្ម។

# ២. សេចក្តីសង្ខេបនៃដំណើរការត្រួតពិនិត្យគុណភាព

## ២.១. គោលបំណងនៃការត្រួតពិនិត្យគុណភាព

- ធ្វើចំណាត់ថ្នាក់ និងជាគំរូផលិតផលធៀបទៅនឹងស្តង់ដារគុណភាពគ្រាប់ពូជ
- ជំរុញអាជីវកម្មគ្រាប់ពូជស្រូវប្រកបដោយយុត្តិធម៌និងប្រសិទ្ធភាព
- បង្ហាញសូចនាករជាក់លាក់អំពីគុណភាពនៃផលិតផលគ្រាប់ពូជដល់អ្នកទិញយកទៅផលិត។

## ២.២. វិធានការគ្រប់គ្រងគុណភាពគ្រាប់ពូជស្រូវ

ហានិភ័យមួយចំនួនមានជាប់ឬលាយឡំជាមួយគ្រាប់ពូជនៅក្នុងដំណើរការផលិតកម្មគ្រាប់ពូជស្រូវ ដែលមន្ត្រីត្រួតពិនិត្យគុណភាពគួរពិចារណាស្របតាមនីតិវិធីប.គ.៣។ ការត្រួតពិនិត្យគុណភាពត្រឹមត្រូវនឹងអាចបន្ថយហានិភ័យនៃការលាយឡំទាំងនោះបាន។ ដំណើរការត្រួតពិនិត្យគុណភាពគ្រាប់ពូជស្រូវ រួមមាន៖ (១)ការពិនិត្យឯកសារ (២)ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាល (៣)ការយកសំណាកនិងការត្រួតពិនិត្យគុណភាពគ្រាប់ពូជនៅមន្ទីរពិសោធន៍ និង (៤)ស្វ័យត្រួតពិនិត្យគុណភាពនៃអ្នកផលិតគ្រាប់ពូជ ដើម្បីប្រាកដថាភាពសុទ្ធនៃគ្រាប់ពូជត្រូវបានបញ្ជាក់ ឬធានា។

| ហានិភ័យ | | វិធានការ |
|---|---|---|
| ១ | ការលាយឡំមកជាមួយគ្រាប់ពូជគ្រឹះ ឬគ្រាប់ពូជចុះបញ្ជី | • ប្រើប្រាស់គ្រាប់ពូជគ្រឹះ ឬគ្រាប់ពូជចុះបញ្ជីដែលស្របតាមស្តង់ដារត្រឹមត្រូវ និងមានប្រភពច្បាស់លាស់។ |
| ២ | សំណល់គ្រាប់ពូជផ្សេងក្នុងស្រែកាលពីរដូវដាំដុះមុន | • ជ្រើសរើសដីស្រែដែលធ្លាប់ដាំប្រភេទពូជដដែល ឬដំណាំផ្សេងគ្រាប់តូចៗមិនមែនជាស្រូវឱ្យបានយ៉ាងហោច(១) រដូវ<br>• សម្អាតដីស្រែដោយទុកឱ្យគ្រាប់ពូជផ្សេងដុះអស់ រួចប្រើប្រាស់ថ្នាំស្មៅប្រភេទមិនជ្រើសរើសដើម្បីសម្លាប់មួរ ឬសាស្រូវ និងប្រើប្រាស់វិធានការក្សេត្រសាស្ត្រផ្សេងទៀត។ |
| ៣ | ការលាយឡំជាមួយគ្រាប់ពូជមានជំងឺហាមឃាត់ | • ប្រើប្រាស់ថ្នាំកសិកម្មដោយប្រឡាក់គ្រាប់ពូជមុនដាំ<br>• គ្រប់គ្រងជំងឺហាមឃាត់ឱ្យបានត្រឹមត្រូវទៅតាមស្តង់ដារទីវាល។ |
| ៤ | ការលាយឡំជាមួយគ្រាប់ពូជស្មៅហាមឃាត់ | • គ្រប់គ្រងស្មៅឱ្យបានត្រឹមត្រូវទៅតាមស្តង់ដារទីវាល។ |
| ៥ | ការលាយឡំជាមួយគ្រាប់ពូជស្រូវផ្សេងក្នុងពេលប្រមូលផល | • ទុកគម្លាតស្រែផលិតកម្មគ្រាប់ពូជស្រូវឱ្យឆ្ងាយពីស្រែផលិតកម្មស្រូវផ្សេង |

| | | |
|---|---|---|
| | | • សម្អាតម៉ាស៊ីនច្រូតឱ្យបានត្រឹមត្រូវមុនពេលប្រមូលផលគ្រាប់ពូជស្រូវ។ |
| ៦ | ការលាយជាមួយគ្រាប់ពូជផ្សេងក្នុងអំឡុងពេលកែច្នៃគ្រាប់ពូជ និងវេចខ្ចប់ | • ពិនិត្យដំណើរការអនុវត្តសកម្មភាពក្រោយការប្រមូលផល និងស្វ័យត្រួតពិនិត្យគុណភាពគ្រាប់ពូជឱ្យបានត្រឹមត្រូវ<br>• ពិនិត្យសាឡើងវិញសំបកបាវវេចខ្ចប់ជាមួយឈ្មោះពូជស្រូវ។ |
| ៧ | ការច្រឡំអំឡុងពេលយកសំណាក និងវិភាគគ្រាប់ពូជស្រូវ | • ដាក់ស្លាកសម្គាល់ឱ្យបានត្រឹមត្រូវបន្ទាប់ពីយកសំណាកគ្រាប់ពូជរួច។ |
| ៨ | ការវេចខ្ចប់និងបិទស្លាកសញ្ញាខុស | • ពិនិត្យសំបកវេចខ្ចប់គ្រាប់ពូជសម្រាប់លក់ ព្រមទាំងស្លាកសញ្ញាបញ្ជាក់គុណភាព **ប.គ.ព** ដែលត្រូវបិទភ្ជាប់។ |



## ២.៣. ដំណើរការត្រួតពិនិត្យគុណភាពគ្រាប់ពូជស្រូវតាម ប.គ.ព




### គំនូសបំព្រួញក្នុងដំណើរការត្រួតពិនិត្យគុណភាពគ្រាប់ពូជស្រូវតាម ប.គ.ព

| អ្នកទទួលបន្ទុក | | ឯកសារពាក់ព័ន្ធ |
|---|---|---|
| អ្នកផលិត/ កសិករចុះកិច្ចសន្យា | **ការធ្វើផែនការផលិតកម្មគ្រាប់ពូជ**<br>ចុះកិច្ចសន្យាជាមួយកសិករផលិតគ្រាប់ពូជ និងពិនិត្យស្រែផលិតកម្ម | |
| អ្នកផលិត >>> PDAFF/GDA | **ការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ**<br>ព័ត៌មាននៃផលិតករគ្រាប់ពូជ និងផែនការរបស់អ្នកផលិតគ្រាប់ពូជស្រូវ<br>(ដាក់៣(បី)ខែមុនពេលដំណើរការផលិតកម្មគ្រាប់ពូជ) | ឧបសម្ព័ន្ធ 1-A |
| GDA | **ការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ**<br>ផ្តល់ជូនដោយ GDA<br>(អំឡុងពេល២០ថ្ងៃបន្ទាប់ពីទទួលពាក្យស្នើសុំ) | ឧបសម្ព័ន្ធ 1-B |
| អ្នកផលិត >>> PDAFF/GDA | **ការដាក់ទម្រង់(ក)៖ ផែនការផលិតកម្មគ្រាប់ពូជស្រូវប្រចាំរដូវ**<br>ប្រភពគ្រាប់ពូជ, ផ្ទៃដីដាំដុះ។ល។<br>(យ៉ាងហោចណាស់២០ថ្ងៃមុនផលិតកម្មគ្រាប់ពូជស្រូវ) | ឧបសម្ព័ន្ធ 1-C |
| អ្នកផលិត/ កសិករចុះកិច្ចសន្យា | **ដំណើរការផលិតកម្មគ្រាប់ពូជក្នុងស្រែដែលបានកំណត់**<br>ស្វ័យគ្រប់គ្រងត្រួតពិនិត្យគុណភាពផលិតកម្មទីវាល | |
| មន្ត្រីត្រួតពិនិត្យ PDAFF/DCS | **ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលលើកទី១ និងការធ្វើរបាយការណ៍**<br>ត្រួតពិនិត្យមុនពេលចេញផ្កា និងធ្វើរបាយការណ៍ភ្លាមបន្ទាប់ពីត្រួតពិនិត្យគុណភាព | ឧបសម្ព័ន្ធ 1-D/1-E |
| មន្ត្រីត្រួតពិនិត្យ PDAFF/DCS | **ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលលើកទី២ និងការធ្វើរបាយការណ៍**<br>ត្រួតពិនិត្យក្នុងដំណាក់កាលស្រូវដាក់រម្យៅ និងធ្វើរបាយការណ៍ភ្លាមបន្ទាប់ពីត្រួតពិនិត្យគុណភាព | ឧបសម្ព័ន្ធ 1-D/1-E |
| អ្នកផលិត/ | **ការងារប្រមូលផល និងក្រោយប្រមូលផល** | |

## គំនូសបំព្រួញក្នុងដំណើរការត្រួតពិនិត្យគុណភាពគ្រាប់ពូជស្រូវតាម ប.គ.ព

| អ្នកទទួលបន្ទុក | | ឯកសារពាក់ព័ន្ធ |
|---|---|---|
| កសិករចុះកិច្ចសន្យា | ត្រួតពិនិត្យគុណភាពក្នុងពេលប្រមូលផល សម្ងួត កែច្នៃ វេចខ្ចប់ និងរក្សាទុក | |
| អ្នកផលិត/<br>កសិករចុះកិច្ចសន្យា | **ស្វ័យចាត់ចែងឡូត៍គ្រាប់ពូជ**<br>ចាត់ចែងឡូត៍គ្រាប់ពូជផ្អែកលើកសិករចុះកិច្ចសន្យា ពូជ ថ្នាក់គ្រាប់ពូជ រដូវកាល ឆ្នាំផលិត និងស្រែ | |
| អ្នកផលិត/<br>កសិករចុះកិច្ចសន្យា | **ស្វ័យត្រួតពិនិត្យគុណភាពគ្រាប់ពូជបឋម**<br>ភាពសុទ្ធ កម្ទេចកម្ទី គ្រាប់ស្មៅ គ្រាប់ពូជស្រូវផ្សេង គ្រាប់ដំណាំផ្សេង ស្រូវក្រហម សំណើមគ្រាប់ និង ដំណុះគ្រាប់ពូជ | |
| អ្នកផលិត >>><br>PDAFF/GDA | **ការដាក់ទម្រង់(ខ)៖ សំណើសុំត្រួតពិនិត្យគុណភាពគ្រាប់ពូជ**<br>ដាក់ជូន PDAFF/GDA | ឧបសម្ព័ន្ធ<br>1-F |
| មន្ត្រីត្រួតពិនិត្យ<br>PDAFF/DCS | **ការយកសំណាកសម្រាប់ត្រួតពិនិត្យគុណភាពនៅមន្ទីរពិសោធន៍**<br>ត្រូវយកសំណាកឱ្យបានត្រឹមត្រូវ | |
| មន្ត្រីត្រួតពិនិត្យ<br>NAL/PDAFF | **ការវិភាគគុណភាពគ្រាប់ពូជនៅមន្ទីរពិសោធន៍**<br>ភាពសុទ្ធ កម្ទេចកម្ទី គ្រាប់ស្មៅ គ្រាប់ពូជស្រូវផ្សេង គ្រាប់ដំណាំផ្សេង ស្រូវក្រហម សំណើមគ្រាប់ និង ដំណុះគ្រាប់ពូជ | |
| មន្ត្រីត្រួតពិនិត្យ<br>NAL/PDAFF | **របាយការណ៍វិភាគគុណភាពគ្រាប់ពូជ**<br>បង្ហាញលទ្ធផលវិភាគ និងសេចក្ដីសន្និដ្ឋាន | ឧបសម្ព័ន្ធ<br>1-G/1-F |
| GDA >>><br>អ្នកផលិត | **ការជូនព័ត៌មានអំពីលទ្ធផលនៃការវិភាគគុណភាពគ្រាប់ពូជដល់អ្នកផលិតគ្រាប់ពូជ**<br>សម្រេច បដិសេធ ឬស្នើឱ្យចាត់វិធានការកែលម្អក្នុងអំឡុងពេល ៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ | |
| GDA >>><br>អ្នកផលិត | **ការផ្ដល់ស្លាកសញ្ញាបញ្ជាក់គុណភាព ប.គ.ព**<br>ផ្ដល់ស្លាកសញ្ញាបញ្ជាក់គុណភាព ប.គ.ព ជូនផលិតករទៅតាមការដាក់ពាក្យទម្រង់(ខ) | |

# ៣. ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាល

## ៣.១. គោលបំណង និងទិដ្ឋភាពត្រួតពិនិត្យគុណភាពផលិតកម្មទីវាល

ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលត្រូវធ្វើឡើងយ៉ាងហោចណាស់ចំនួន២(ពីរ)ដងក្នុងអំឡុងពេលផលិតកម្មគ្រាប់ពូជ។ ការត្រួតពិនិត្យគុណភាពផលិតកម្មនៅទីវាលលើកទី១ធ្វើឡើងដំណាក់កាលមុនចេញផ្កា និងលើកទី២នៅដំណាក់កាលស្រូវដាក់ម្សៅ។ ក្នុងករណីលទ្ធផលនៃការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលលើកទី២ មិនបានស្របតាមស្តង់ដារទីវាល ប៉ុន្តែអាចកែលម្អបាន ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលគួរតែធ្វើសាឡើងវិញ ដូចមានចែងនៅចំណុច **២.៧.៥** នៃសៀវភៅស្តីពី **ប.គ.ព** សម្រាប់ផលិតកម្មនិងអាជីវកម្មគ្រាប់ពូជស្រូវ។

### ៣.១.១. ការត្រួតពិនិត្យគុណភាពផលិតកម្មនៅទីវាលលើកទី១ នៅដំណាក់កាលមុនពេលចេញផ្កា

<u>គោលបំណងនៃការត្រួតពិនិត្យគុណភាពផលិតកម្មទីវាល</u>

- ដើម្បីផ្តល់ប្រឹក្សាសមស្របដល់អ្នកផលិតគ្រាប់ពូជឱ្យអនុវត្តស្របទៅតាមស្តង់ដារទីវាល។

<u>ទិដ្ឋភាពត្រួតពិនិត្យគុណភាពផលិតកម្មទីវាល</u>

១. ពិនិត្យប្រភពគ្រាប់ពូជយកមកប្រើប្រាស់ក្នុងផលិតកម្ម ដូចជាព័ត៌មានលើសំបកបាវវេចខ្ចប់ ស្លាកបិទភ្ជាប់វិក្កយបត្រ ជាដើម។ល។

២. ពិនិត្យគម្លាត និងប្រវត្តិដាំដុះនៃស្រែផលិតកម្ម

៣. រាប់ចំនួនដើមពូជលាយក្នុងផ្ទៃដីដែលបានត្រួតពិនិត្យលើផ្ទៃដី១ម៉ែត្រការ៉េ ចំនួន១០កន្លែង

៤. រាប់ចំនួនស្មៅហាមឃាត់ក្នុងផ្ទៃដីដែលបានត្រួតពិនិត្យលើផ្ទៃដី១ម៉ែត្រការ៉េ ចំនួន១០កន្លែង

៥. វាយតម្លៃស្ថានភាពជំងឺក្នុងផ្ទៃដីដែលបានត្រួតពិនិត្យលើផ្ទៃដី១ម៉ែត្រការ៉េ ចំនួន១០កន្លែង

៦. ត្រួតពិនិត្យស្ថានភាពទូទៅនៃស្រែដែលបានត្រួតពិនិត្យគុណភាពទាំងមូល រួមទាំងការគ្រប់គ្រងផលិតកម្មផងដែរ។

### ៣.១.២. ការត្រួតពិនិត្យគុណភាពផលិតកម្មនៅទីវាលលើកទី២ នៅដំណាក់កាលដាក់ម្សៅ

<u>គោលបំណងនៃការត្រួតពិនិត្យគុណភាពផលិតកម្មទីវាល</u>

- ដើម្បីវាយតម្លៃថាតើស្រែផលិតកម្មគ្រាប់ពូជស្រូវស្របទៅតាមស្តង់ដារទីវាលដែរឬទេ និងដើម្បីអនុញ្ញាតឱ្យអ្នកផលិតគ្រាប់ពូជប្រមូលផលសម្រាប់ការកែច្នៃជាផលិតផលគ្រាប់ពូជស្រូវសម្រេច។

<u>ទិដ្ឋភាពត្រួតពិនិត្យគុណភាពផលិតកម្មទីវាលៈ</u>

១. រាប់ចំនួនដើមពូជលាយក្នុងផ្ទៃដីដែលបានត្រួតពិនិត្យលើផ្ទៃដី១ម៉ែត្រការ៉េ ចំនួន១០កន្លែង

២. រាប់ចំនួនស្មៅហាមឃាត់ ក្នុងផ្ទៃដីដែលបានត្រួតពិនិត្យលើផ្ទៃដី១ម៉ែត្រការ៉េ និងចំនួន១០កន្លែង

៣. វាយតម្លៃស្ថានភាពជំងឺក្នុងផ្ទៃដីដែលបានត្រួតពិនិត្យលើផ្ទៃដី១ម៉ែត្រការ៉េ និងចំនួន១០កន្លែង

៤. វាយតម្លៃភាគរយនៃការបំផ្លាញដោយជំងឺហាមឃាត់ក្នុងស្រែផលិតកម្មគ្រាប់ពូជ ដែលបានត្រួតពិនិត្យទាំងមូល ។

### ៣.១.៣. ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលសម្រាប់ស្រែជំនួស ក្នុងករណីចាំបាច់

<u>គោលបំណងនៃការត្រួតពិនិត្យគុណភាពផលិតកម្មទីវាល</u>

- ដើម្បីពិនិត្យមើលថាតើស្រែផលិតកម្មគ្រាប់ពូជស្រូវជំនួសស្របទៅតាមស្តង់ដារទីវាលដែរ ឬទេ នៅពេលដែលស្រែផលិតកម្មដែលបានជ្រើសរើស ឬត្រួតពិនិត្យលើកទី១ រងការបំផ្លាញដោយសារប្រធានស័ក្ត។

<u>ទិដ្ឋភាពត្រួតពិនិត្យគុណភាពផលិតកម្មទីវាល</u>

១. រាប់ចំនួនដើមពូជលាយក្នុងផ្ទៃដីដែលបានត្រួតពិនិត្យលើផ្ទៃដី១ម៉ែត្រការ៉េ ចំនួន១០កន្លែង

២. រាប់ចំនួនស្មៅហាមឃាត់ដែលអាចជះឥទ្ធិពលលើគុណភាពគ្រាប់ពូជក្នុងផ្ទៃដីដែលបានត្រួតពិនិត្យលើផ្ទៃដី១ម៉ែត្រការ៉េ ចំនួន១០កន្លែង

៣. វាយតម្លៃស្ថានភាពជំងឺក្នុងផ្ទៃដីដែលបានត្រួតពិនិត្យលើផ្ទៃដី១ម៉ែត្រការ៉េ ចំនួន១០កន្លែង

៤. វាយតម្លៃភាគរយនៃការបំផ្លាញដោយជំងឺហាមឃាត់ក្នុងស្រែផលិតកម្មគ្រាប់ពូជទាំងមូលដែលបានត្រួតពិនិត្យ។

## ៣.២. ផ្ទៀងផ្ទាត់ប្រភពគ្រាប់ពូជគ្រឹះ ឬគ្រាប់ពូជចុះបញ្ជី

១. នៅក្នុងដំណាក់កាលត្រួតពិនិត្យគុណភាពផលិតកម្មទីវាលលើកទី១ ត្រូវពិនិត្យស្លាកឬស្លាកសញ្ញាបាវវេចខ្ចប់គ្រាប់ពូជ និងវិក្កយបត្រនៃគ្រាប់ពូជគ្រឹះ ឬគ្រាប់ពូជចុះបញ្ជី។

២. គ្រាប់ពូជគ្រឹះ ឬគ្រាប់ពូជចុះបញ្ជីគួរតែមានប្រភពច្បាស់លាស់ពីអង្គភាពឬគ្រឹះស្ថានផលិតគ្រាប់ពូជដែល មានការអនុញ្ញាតស្របច្បាប់ដូចជា វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា(CARDI) និងស្ថានីយកសិកម្មដែលមានការទទួលស្គាល់ និងក្រុមហ៊ុននាំចូល។ល។

៣. ណែនាំអ្នកផលិតគ្រាប់ពូជឱ្យរក្សាទុកស្លាកឬស្លាកសញ្ញា បាវវេចខ្ចប់គ្រាប់ពូជ និងវិក្កយបត្រសម្រាប់គោលបំណងនៃការត្រួតពិនិត្យគុណភាពផលិតកម្មទីវាល។




ស្លាកសញ្ញា/សំបកវេចខ្ចប់ វិក្កយបត្រ

## ៣.៣. លក្ខខណ្ឌតម្រូវសម្រាប់ជ្រើសរើសស្រែផលិតកម្ម

១. ប្រភេទពូជស្រូវតែមួយ ឬប្រភេទដំណាំផ្សេង ត្រូវបានដាំដុះនៅក្នុងស្រែកាលពី១(មួយ)ឆ្នាំកន្លងមកសម្រាប់ពូជស្រូវប្រកាន់រដូវ ឬ១(មួយ)រដូវកន្លងមកសម្រាប់ពូជស្រូវមិនប្រកាន់រដូវ។




PRD=ពូជស្រូវផ្ការំដួល, SKO-01=ពូជស្រូវសែនក្រអូប០១, OM5451=ពូជស្រូវអូអឹម

២. ស្រែមិនត្រូវមានស្រូវដុះសា ឬដុះមួរ។

៣. ទំហំផ្ទៃដីផលិតកម្មអប្បបរមារបស់អ្នកផលិតគ្រាប់ពូជ ដែលសមស្របនិងអនុញ្ញាតសម្រាប់ថ្នាក់គ្រាប់ពូជមួយ និងប្រភេទពូជមួយ មានចែងដូចខាងក្រោម៖

| ថ្នាក់គ្រាប់ពូជ | គ្រាប់ពូជគ្រឹះ | គ្រាប់ពូជចុះបញ្ជី | គ្រាប់ពូជវិញ្ញាបនបត្រ |
|---|---|---|---|
| ទំហំស្រែអប្បបរមា | ០.២០ ហ.ត | ០.៥០ ហ.ត | ៥.០០ ហ.ត |

៤. ស្រែផលិតកម្មនីមួយៗត្រូវមានទំហំអប្បបរមា ដែលអាចអនុញ្ញាតសម្រាប់ថ្នាក់គ្រាប់ពូជមួយ និងប្រភេទពូជមួយ មានចែងដូចខាងក្រោម៖

| ថ្នាក់គ្រាប់ពូជ | គ្រាប់ពូជគ្រឹះ | គ្រាប់ពូជចុះបញ្ជី | គ្រាប់ពូជវិញ្ញាបនបត្រ |
|---|---|---|---|
| ទំហំស្រែអប្បបរមា | ០.២០ ហ.ត | ០.៥០ ហ.ត | ០.៥០ ហ.ត |

៥. ស្រែផលិតកម្មគ្រាប់ពូជត្រូវតែឃ្លាតពីស្រែប្រភេទពូជស្រូវផ្សេងទៀតចម្ងាយ១(មួយ)ម៉ែត្រ ឬដោយរបាំងទីតាំង ដូចជាៈ ប្រឡាយ របងឈើរស់ របង។ល។




**គម្លាត**

ស្រែផលិតកម្មគ្រាប់ពូជត្រូវតែឃ្លាតឆ្ងាយពីស្រែពូជស្រូវផ្សេងចម្ងាយយ៉ាងហោចណាស់១ម។

**របាំងទីតាំង**

ក្នុងករណីមានរបាំងទីតាំង ដូចជាៈ ប្រឡាយ, របងឈើរស់ ឬរបង ដូច្នេះគម្លាតមិនតម្រូវឱ្យមាននោះទេ។

**ករណីលើកលែង**

ក្នុងករណីពូជស្រូវដូចគ្នាត្រូវបានដាំដុះស្រែក្បែរគ្នា ដូច្នេះគម្លាតមិនតម្រូវឱ្យមានសម្រាប់ផលិតកម្មវិញ្ញាបនបត្រនោះទេ។

៦. វិធីសាស្ត្រស្ទូងជាជួរ ១ដើម ក្នុងមួយដំណោត ត្រូវអនុវត្តសម្រាប់ផលិតកម្មគ្រាប់ពូជគ្រឹះ និង១-៣ ដើម ក្នុងមួយដំណោតសម្រាប់ផលិតកម្មគ្រាប់ពូជចុះបញ្ជី។ វិធីសាស្ត្រស្ទូងធម្មតា ឬដាំគ្រាប់ត្រង់ជួរ ត្រូវអនុវត្តសម្រាប់ផលិតកម្មគ្រាប់ពូជវិញ្ញាបនបត្រ។




## ៣.៤. ការជ្រើសរើសផ្ទៃដីយកសំណាក

១. ផ្ទៃដីអប្បបរមា១០%នៃផ្ទៃដីផលិតកម្មគ្រាប់ពូជសរុបនៃប្រភេទពូជនីមួយៗត្រូវបានជ្រើសរើសដោយចៃដន្យដោយមន្ត្រីត្រួតពិនិត្យគុណភាពនៃនាយកដ្ឋានពូជដំណាំនៃអគ្គនាយកដ្ឋានកសិកម្ម ឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត សម្រាប់ត្រួតពិនិត្យគុណភាពផលិតកម្មទីវាល។

ផ្ទៃដីសម្រាប់យកសំណាកត្រូវតែជ្រើសរើសទៅតាមអ្នកផលិតគ្រាប់ពូជ រដូវដាំដុះ ឈ្មោះពូជ និងថ្នាក់គ្រាប់ពូជ។



ផ្ទៃដីត្រួតពិនិត្យគុណភាពផលិតកម្មទីវាលត្រូវបានជ្រើសរើសដោយចៃដន្យទៅតាមប្រភេទពូជ ថ្នាក់គ្រាប់ពូជ និងរដូវកាលដាំដុះ។

២. ផ្ទៃដីស្រែសម្រាប់ត្រួតពិនិត្យគុណភាពផលិតកម្មទីវាល អាចតែ១ស្រែ ឬច្រើនស្រែ។ បន្ទាប់ពីការជ្រើសរើសស្រែសម្រាប់ត្រួតពិនិត្យគុណភាពផលិតកម្មទីវាលរួច ត្រូវជ្រើសរើសផ្ទៃដីសំណាកទំហំ១ម៉ែត្របួនជ្រុងចំនួន១០កន្លែងចេញពីស្រែនីមួយៗ ដែលបានជ្រើសរើសដោយចៃដន្យរួច ដើម្បីត្រួតពិនិត្យគុណភាពផលិតកម្មទីវាល។



## ករណីទី២




៣. ផ្ទៃដីយកសំណាកត្រូវជ្រើសរើសដោយចៃដន្យចេញពីស្រែដែលបានកំណត់រួចសម្រាប់ការត្រួតពិនិត្យគុណភាពផលិតកម្មនៅទីវាល។




ឧទាហរណ៍ទី១




ឧទាហរណ៍ទី២



ផ្ទៃដីក្នុង១សំណាក ( ១ម x ១ម )




**x ១០ទីតាំង = ១០ម² ក្នុងមួយស្រែយកសំណាក**

## ៣.៥. ស្តង់ដារគុណភាពផលិតកម្មនៅទីវាល

ពូជលាយ ស្មៅហាមឃាត់ និងជំងឺហាមឃាត់ត្រូវរាប់នៅក្នុងទំហំផ្ទៃដីយកសំណាកនៃស្រែត្រួតពិនិត្យគុណភាពផលិតកម្មទីវាល។ ស្តង់ដារទីវាលបានកំណត់កម្រិតអនុញ្ញាតអតិបរមាដូចខាងក្រោម៖

| ប្រភេទ | បរិយាយលម្អិត | ស្តង់ដារក្នុងផ្ទៃដីទំហំ១០ម$^{២}$ | | |
|---|---|---|---|---|
| | | ពូជគ្រឹះ | ពូជចុះបញ្ជី | ពូជវិញ្ញាបនបត្រ |
| ពូជលាយ | ពូជស្រូវផ្សេង រាប់បញ្ចូលទាំងស្រូវក្រហម | ០ | មិនលើសពី១ដើម ឬ១កួរ | មិនលើសពី៣ដើម ឬ ៣កួរ |
| ស្មៅហាមឃាត់ | ១. ស្មៅបែកក្បាល ( *Echinochloa* spp. )<br>២. ស្មៅកន្ទុយក្ងោក ( *Leptochloa chinensis* )<br>៣. កក់ធំត្រង់ ( *Cyperus iria* ) | ០ | មិនលើសពី៥ដើម ឬ៥កួរ | មិនលើសពី ១០ដើម ឬ ១០កួរ |
| ជំងឺហាមឃាត់ | ១. ប្លាស់ ( Blast )<br>២. អុចត្នោត ( Brown spot )<br>៣. រលាកស្រទបស្លឹក ( Sheath blight ) | មិនលើសពី៥០%នៃផ្ទៃដីស្រែផលិតកម្មដែលបានត្រួតពិនិត្យគុណភាពផលិតកម្មទីវាល។ | | |

## ៣.៦. ការកំណត់ប្រភេទពូជលាយ

### ៣.៦.១. ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលលើកទី១នៅដំណាក់កាលមុនចេញផ្កា

ដើម្បីកំណត់ពូជលាយដោយរាប់បញ្ចូលទាំងស្រូវក្រហមផង ត្រូវពិនិត្យ ១)កម្ពស់រុក្ខជាតិ ២)ពេលវេលាចេញកួរ និង៣)ចំនួនដើមបែក។ ប្រសិនបើរកឃើញមានប្រភេទពូជលាយត្រូវណែនាំអ្នកផលិតគ្រាប់ពូជឱ្យដកវាចោល។ ប្រសិនបើចំនួនពូជលាយរកឃើញលើសពីស្តង់ដារកំណត់ត្រូវណែនាំអ្នកផលិតគ្រាប់ពូជឱ្យដកវាចោល រួចហើយត្រួតពិនិត្យម្តងទៀតនៅពេលក្រោយ។



### ៣.៦.២. ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលលើកទី២នៅដំណាក់កាលដាក់ម្សៅ

ដើម្បីកំណត់ពូជលាយត្រូវពិនិត្យ ១)ពណ៌និងការទុំនៃដំណាំ ២)ពណ៌និងទម្រង់កួរ និង៣)ពណ៌ទម្រង់និងចំនួនគ្រាប់ស្រូវ។







**A** ពូជលាយមុនចេញផ្កា មិនជះឥទ្ធិពលដល់គុណភាពគ្រាប់ពូជទេ។

**B** ពូជលាយក្នុងដំណាក់កាលទុំ មិនត្រូវឱ្យមានទេ។

## ៣.៧. ការកំណត់ស្មៅហាមឃាត់

ស្មៅ៣(បី)ប្រភេទត្រូវបានកំណត់ជាប្រភេទស្មៅហាមឃាត់ក្នុងផលិតកម្មគ្រាប់ពូជស្រូវតាម **ប.គ.៣**។

| ស្មៅបែកក្បាល | ស្មៅកន្ទុយក្ងោក | កក់ផ័ត្រធំ |
| --- | --- | --- |
|  |  |  |
| *Echinochloa* | *Leptochloa* | *Cyperus* |

### ៣.៧.១. ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលលើកទី១នៅដំណាក់កាលមុនចេញផ្កា

ពិនិត្យស្ថានភាពស្មៅនៅក្នុងស្រែ បន្ទាប់មកផ្តល់ប្រឹក្សាដល់អ្នកផលិតគ្រាប់ពូជ ស្តីពីបច្ចេកទេសគ្រប់គ្រងស្មៅ។ មន្ត្រីត្រួតពិនិត្យគុណភាពត្រូវពន្យល់ថាតើស្មៅប្រភេទណាមិនអាចទទួលយកបានក្នុងការត្រួតពិនិត្យគុណភាពទីវាលលើកទី២។




### ៣.៧.២. ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលលើកទី២នៅដំណាក់កាលដាក់ម្សៅ

ពិនិត្យមើលថាតើស្មៅហាមឃាត់ដែលបានរកឃើញអាចទទួលយកបានទេធៀបទៅនឹងស្តង់ដារទីវាល។ ប្រភេទស្មៅតូចៗគ្មានផ្កា គួរតែមិនបាច់យកចិត្តទុកដាក់ទេ ព្រោះវាមិនធ្វើឱ្យប៉ះពាល់ដល់គុណភាពគ្រាប់ពូជស្រូវ។




**A** ស្មៅហាមឃាត់គ្មានផ្កា មិនជះឥទ្ធិពលដល់គុណភាពគ្រាប់ពូជទេ។

**B** ស្មៅហាមឃាត់ដែលមានផ្កា មិនត្រូវឱ្យមានទេ។

## ៣.៨. ការកំណត់ជំងឺហាមឃាត់

ជំងឺហាមឃាត់៣(បី)ប្រភេទ ដូចជាៈ ជំងឺប្លាស់ ជំងឺអុចត្នោត និងជំងឺរលាកស្រទបស្លឹក ត្រូវតែគ្រប់គ្រងឱ្យបានត្រឹមត្រូវនៅក្នុងស្រែផលិតកម្ម។

### ៣.៨.១. ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលលើកទី១នៅមុនដំណាក់កាលចេញផ្កា

ដើម្បីកំណត់វត្តមានជំងឺត្រូវពិនិត្យមើលរោគសញ្ញាជំងឺលើស្លឹក និងដើមរបស់ដំណាំស្រូវ។ ប្រសិនបើរកឃើញវត្តមានជំងឺ ត្រូវផ្តល់ប្រឹក្សាជាមួយអ្នកផលិតគ្រាប់ពូជស្តីពីបច្ចេកទេសគ្រប់គ្រងជំងឺ។ ជាទូទៅ នៅពេលប្រើប្រាស់ជីអាសូតលើសលុបអាចបណ្តាលឱ្យកើតមានជំងឺប្លាស់ ចំណែកកង្វះអាសូតគឺបង្កឱ្យកើតមានជំងឺអុចត្នោត។

| ជំងឺប្លាស់ | ជំងឺអុចត្នោត | ជំងឺរលាកស្រទបស្លឹក | ការខូចមិនមែនជាជំងឺ |
|---|---|---|---|
|  |  |  |  |
| សណ្ឋានរាងស្រួចត្រង់មានពណ៌ត្នោតនិងលឿងលេចឡើងតាមបណ្តោយស្លឹក | សណ្ឋានរាងមូលមានពណ៌ត្នោតចាស់និងលឿងលេចឡើងនៅលើស្លឹក | ជំងឺចាប់ផ្តើមបំផ្លាញពីផ្នែកខាងក្រោមនៃស្រទបស្លឹក | រូបភាពនេះមិនមែនជាជំងឺទេ ប៉ុន្តែជាភាពមិនប្រក្រតីនៃសរីរសាស្ត្ររបស់រុក្ខជាតិ |

### ៣.៨.២. ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលលើកទី២នៅដំណាក់កាលដាក់ម្សៅ

រោគសញ្ញាបំផ្លាញខ្លះនៅកួរស្រូវគឺអាចបណ្តាលមកពីដង្កូវស៊ីរូងដើម ឬហេតុផលផ្សេងទៀត។ ដូច្នេះត្រូវពិនិត្យទាំងស្លឹកនិងទាំងកួររបស់ស្រូវ។

| ជំងឺប្លាស់ | ជំងឺអុចត្នោត | ជំងឺរលាកស្រទបស្លឹក | ការខូចមិនមែនជាជំងឺ |
|---|---|---|---|
|  |  |  |  |
| ការបំផ្លាញភាគច្រើនរកឃើញនៅលើចង្កុំស្លឹកក្រោមកួរស្រូវ | កួរស្រូវប្រែជាពណ៌ត្នោតព្រលែត។ ការបំផ្លាញក៏រកឃើញដែរនៅលើស្លឹក | ស្លឹកទង់ជ័យឡើងស្វិតរញម។ ការបំផ្លាញរកឃើញដែរនៅលើស្រទបស្លឹក | ដំណាំរងការបំផ្លាញដោយដង្កូវស៊ីរូងដើម។ កួរស្រូវងាយដកចេញដោយដៃ |

## ៣.៩. ការវិនិច្ឆ័យលើដំណាំស្រូវទទួលរងផលប៉ះពាល់

### ៣.៩.១. ការកំណត់ដំណាំស្រូវទទួលរងផលប៉ះពាល់

ប្រសិនបើដើមស្រូវរងផលប៉ះពាល់ដោយជំងឺហាមឃាត់លើស២៥% ស្រែផលិតកម្មនោះត្រូវចាត់ទុកថាមានជំងឺ។




### ៣.៩.២. ការវាយតម្លៃផលប៉ះពាល់ដោយសារជំងឺហាមឃាត់

ចំនួនគុម្ពស្រូវដែលរងការបំផ្លាញពីជំងឺហាមឃាត់ត្រូវតែតិចជាង៥០% នៅក្នុងស្រែផលិតកម្មគ្រាប់ពូជដែលបានត្រួតពិនិត្យ។ មន្ត្រីត្រួតពិនិត្យគុណភាពត្រូវវាយតម្លៃស្ថានភាពនៃផលប៉ះពាល់ដោយភ្នែក។



# ៤. ការត្រួតពិនិត្យគុណភាពគ្រាប់ពូជស្រូវនៅមន្ទីរពិសោធន៍

## ៤.១. គំនូសបំព្រួញដំណើរការយកសំណាកគ្រាប់ពូជស្រូវ

ផលិតផលគ្រាប់ពូជស្រូវ

▼

មន្ត្រីត្រួតពិនិត្យគុណភាពយកសំណាកដោយអនុលោមទៅតាមវិធានរបស់ អ៊ីសតា (ISTA)

សំណាកបឋម

▼

ប្រសិនបើសំណាកបឋមមានឯកសណ្ឋានភាពពេញលេញ គេត្រូវដាក់វាបញ្ចូលគ្នា

សំណាករួម

▼

សំណាករួមអប្បបរមា៧០០ក្រាមត្រូវបញ្ជូនសម្រាប់ការត្រួតពិនិត្យគុណភាព

សំណាកបញ្ជូន

▼

វេចខ្ចប់/បិទស្លាកសញ្ញា (ឡូត៍គ្រាប់ពូជ ឈ្មោះពូជ ថ្នាក់គ្រាប់ពូជ កាលបរិច្ឆេទប្រមូលផល និងអាសយដ្ឋាននៃអ្នកផលិតគ្រាប់ពូជ)

សំណាកវិភាគ

▼

សំណាកអប្បបរមា៥០០ក្រាមត្រូវបានប្រើសម្រាប់វិភាគភាពសុទ្ធ និងបរិមាណនៅសល់ទុកសម្រាប់វិភាគគុណភាពសាជាថ្មីក្នុងករណីចាំបាច់។

ការវិភាគគុណភាព

## ៤.២. ការយកសំណាកបឋម

- យកសំណាកបឋមចេញពីបាវបានជ្រើសរើសដោយចៃដន្យ ដែលមានបរិមាណប្រហាក់ប្រហែលគ្នា
- ដាក់សំណាកបឋមចូលគ្នាទៅជាសំណាករួមតែមួយ នៅពេលសំណាកបឋមមានឯកសណ្ឋានភាពពេញលេញ។

| ចំនួនបាវ | ចំនួនសំណាកត្រូវការ |
|---|---|
| ១-៤ | ៣ សំណាកក្នុង១បាវ |
| ៥-៨ | ២ សំណាកក្នុង១បាវ |
| ៩-១៥ | ១ សំណាកក្នុង១បាវ |

| ចំនួនបាវ | ចំនួនសំណាកត្រូវការ |
|---|---|
| ១៦-៣០ | ១៥ សំណាកពីបាវផ្សេងៗគ្នា |
| ៣១-៥៩ | ២០ សំណាកពីបាវផ្សេងៗគ្នា |
| >៦០ | ៣០ សំណាកពីបាវផ្សេងៗគ្នា |




## ៤.៣. ការរៀបចំសំណាកបញ្ជូន

- លាយសំណាករួមបញ្ចូលគ្នាឱ្យបានសព្វល្អ
- ដកយកបរិមាណអប្បបរមា៧០០ក្រាមពីសំណាករួមតាមវិធីរំលែកដោយដៃពាក់កណ្តាលស្មើគ្នា
- រក្សាសំណាកដែលនៅសល់ទុកជាសំណាកយោងនៅជាមួយអ្នកផលិតគ្រាប់ពូជ។




**វិធីរំលែកដោយដៃពាក់កណ្តាលស្មើគ្នា**

- ចែកពំនូកជា២(ពីរ)ចំណែក បន្ទាប់មកចែកចំណែកទាំង២នោះដើម្បីទទួលបាន៤(បួន)ចំណែកប្រហាក់ប្រហែលគ្នាដោយប្រើបន្ទះឈើសម្រាប់កៀរញែក
- បន្ទាប់មកដាក់ចំណែកឈមគ្នាបញ្ចូលគ្នា ដើម្បីទទួលបានល្បាយសព្វស្មើគ្នា២(ពីរ)ពំនូក
- ធ្វើសាជាថ្មីនូវនីតិវិធីនេះ ដើម្បីទទួលបានបរិមាណគ្រប់គ្រាន់នៃសំណាក។



## ៤.៤. ការវេចខ្ចប់ និងបិទស្លាកសំណាកបញ្ជូន

- បរិមាណ៧០០ក្រាមនៃសំណាកបញ្ជូនត្រូវវេចខ្ចប់ដែលមានបិទស្លាកព័ត៌មាន
- ព័ត៌មានត្រូវសរសេរលើស្លាកសញ្ញា រួមមាន៖ឡូតិ៍គ្រាប់ពូជ ឈ្មោះពូជ ថ្នាក់គ្រាប់ពូជ កាលបរិច្ឆេទប្រមូលផល និងអាសយដ្ឋានរបស់អ្នកផលិតគ្រាប់ពូជ






បរិមាណអតិបរមា ៧០០ក្រាម នៃសំណាកដែលត្រូវបញ្ជូន។

## ៤.៥. ស្តង់ដារគុណភាពគ្រាប់ពូជស្រូវ

ស្តង់ដារគុណភាពគ្រាប់ពូជស្រូវខាងក្រោមត្រូវបានប្រើប្រាស់សម្រាប់ការវិភាគគុណភាពគ្រាប់ពូជស្រូវ។

| កត្តា | ថ្នាក់គ្រាប់ពូជ | | |
|---|---|---|---|
| | គ្រាប់ពូជគ្រឹះ | គ្រាប់ពូជចុះបញ្ជី | គ្រាប់ពូជវិញ្ញាបនបត្រ |
| ១. គ្រាប់ពូជសុទ្ធ (អប្បបរមា, %) | ៩៨ | ៩៨ | ៩៨ |
| ២. កម្ទេចកម្ទី (អតិបរមា, %) | ២ | ២ | ២ |
| គ្រាប់ពូជស្មៅ (អតិបរមា, ចំនួនគ្រាប់/៥០០ក្រាម) | ៣ | ៥ | ១០ |
| គ្រាប់ពូជដំណាំផ្សេង (អតិបរមា, ចំនួនគ្រាប់/៥០០ក្រាម) | ២ | ៣ | ៥ |
| គ្រាប់ពូជស្រូវផ្សេង (អតិបរមា, ចំនួនគ្រាប់/៥០០ក្រាម) | ១ | ៥ | ១៥ |
| ស្រូវក្រហម (អតិបរមា, ចំនួនគ្រាប់/៥០០ក្រាម) | ០ | ២ | ៥ |
| ៣. អត្រាដំណុះ (អប្បបរមា, %) | ៨៥ | ៨៥ | ៨០ |
| ៤. សំណើមគ្រាប់ពូជ (អតិបរមា, %) | ១២ | ១៣ | ១៤ |

## ៤.៦. ដំណើរការត្រួតពិនិត្យគុណភាពក្នុងមន្ទីរពិសោធន៍

ត្រូវប្រើប្រាស់សំណាកវិភាគ សម្រាប់វិភាគរូបសាស្ត្រ ប្រភេទពូជ ដំណុះគ្រាប់ និងសំណើម។ ចំណែកសំណាកដែលនៅសល់ត្រូវរក្សាទុកជាសំណាកបម្រុង។




## ៤.៧. វិភាគរូបសាស្ត្រ

- យក៧០ក្រាមនៃសំណាកវិភាគ រួចរើសយកកម្ទេចកម្ទីរចេញ ដូចជា៖ ដុំថ្ម ដី ចំបើង គ្រាប់ស្មៅ គ្រាប់ពូជដំណាំផ្សេង គ្រាប់ពូជស្រូវផ្សេង គ្រាប់ខ្ចី គ្រាប់បាក់ដែលនៅសល់តិចជាង ៥០%

**កម្ទេចកម្ទីរ**




a. ដុំថ្ម និងវត្ថុធាតុផ្សេងទៀត
b. គ្រាប់ខ្ចី
c. គ្រាប់បាក់ (បំណែកនៅសល់តិចជាង 50%)

**គ្រាប់ពូជសុទ្ធ**




a. គ្រាប់ពេញ
b. គ្រាប់គ្មានសំបក
c. គ្រាប់បាក់ (បំណែកនៅសល់លើស 50%)

- ថ្លឹងទម្ងន់កម្ទេចកម្ទីរសរុបនៃសំណាក បន្ទាប់មកគណនាភាគរយនៃគ្រាប់ពូជសុទ្ធ។

**កម្ទេចកម្ទី (%)** = ទម្ងន់កម្ទេចកម្ទី (ក្រាម) / ទម្ងន់សំណាក (៧០ក្រាម) X ១០០

**គ្រាប់ពូជសុទ្ធ (%)** = ១០០ (%) — កម្ទេចកម្ទី (%)

ឧ. ទម្ងន់កម្ទេចកម្ទី គឺ <u>១,២ក្រាម។</u>

**កម្ទេចកម្ទី :** ១,២ (ក្រាម) / ៧០ (ក្រាម) X ១០០ = ១,៧ (%)

**គ្រាប់ពូជសុទ្ធ :** ១០០ (%) — ១,៧ (%) = ៩៨,៣ (%)

## ៤.៨. វិភាគប្រភេទពូជ

- រាប់ចំនួនគ្រាប់ពូជស្រូវផ្សេង និងស្រូវក្រហមក្នុងសំណាកវិភាគ៥០០ក្រាម
- ពិនិត្យមើលពណ៌ និងទ្រង់ទ្រាយដើម្បីកំណត់គ្រាប់ពូជស្រូវផ្សេង និងស្រូវក្រហមនៅលើបន្ទះក្តារវិភាគគ្រាប់ពូជ
- ពិនិត្យមើលកម្ទេចកម្ទីផ្សេងទៀត ដូចជា៖ គ្រាប់អង្ករបាក់ដែលនៅសល់ក្រោម៥០% គ្រាប់ខ្ចី គ្រាប់ស្មៅ ដុំថ្ម ឬវត្ថុធាតុផ្សេងទៀត។




ឧទាហរណ៍នៃគ្រាប់ពូជស្រូវផ្សេង

## ៤.៩. វិភាគសំណើមគ្រាប់




- ជ្រើសរើសពាក្យ 'Paddy' សម្រាប់វាស់សំណើមរបស់គ្រាប់ពូជស្រូវ
- វាស់ចំនួន៣ដង រួចគណនារកតម្លៃមធ្យម
- ក្នុងករណីរកឃើញតម្លៃមិនប្រក្រតី ត្រូវវាស់២ដងថែមទៀត រួចហើយលុបចោលតម្លៃមិនប្រក្រតី

បន្ទាប់មកគណនារកតម្លៃមធ្យម

| លើកទី១ | លើកទី២ | លើកទី៣ | លើកទី៤ | លើកទី៥ | មធ្យម |
|---|---|---|---|---|---|
| ១៣,២ | ១៣,៥ | ១៣,៤ | - | - | ១៣,៤ |

| លើកទី១ | លើកទី២ | លើកទី៣ | លើកទី៤ | លើកទី៥ | មធ្យម |
|---|---|---|---|---|---|
| ១៣,៦ | ១៣,៥ | ១៨,៨ | ១៣,៤ | ១២,៩ | ១៣,៥ |
| | | ✕ | | ✕ | |

## ៤.១០. វិភាគដំណុះគ្រាប់

- រៀបចំប្រអប់សម្រាប់ដាក់បណ្ដុះសាកដែលអាចដាក់បាន៤០០គ្រាប់សម្រាប់វិភាគដំណុះគ្រាប់
- ដាក់ក្រដាសជក់ទឹកនៅបាតរបស់ប្រអប់នីមួយៗ រួចរៀបគ្រាប់ពូជចំនួន៤០០គ្រាប់ ដែលចាប់យកដោយចៃដន្យពីសំណាកវិភាគ




- បន្ទាប់ពីរយៈពេល៣(បី)ថ្ងៃ និង៧(ប្រាំពីរ)ថ្ងៃត្រូវរាប់ចំនួនគ្រាប់ពូជដែលដុះសរុប រួចគណនាអត្រាដំណុះ។ គ្រាប់ពូជខ្លះដែលដុះអាចរងការបំផ្លាញដោយសារជំងឺផ្សិត ឬងាប់។ ក្នុងករណីនេះ មិនត្រូវរាប់គ្រាប់ពូជទាំងនោះជាគ្រាប់ពូជដុះទេ។



មិនដុះ


ដុះធម្មតា


ដុះល្អ

**ទម្រង់កត់ត្រាតេស្តដំណុះ**

| ថ្ងៃ | ដុះធម្មតា (A) | ដុះខ្សោយ (B) | គ្រាប់រឹង (C) | ងាប់ ឬ ខូច* (D) | ដុះសរុប (A)+(B) |
|---|---|---|---|---|---|
| ថ្ងៃទី១ | ០ | ០ | ០ | ០ | ០ |
| ថ្ងៃទី២ | ៣៦ | ០ | ០ | ០ | ៣៦ |
| ថ្ងៃទី៣ | ១៥៤ | ៥ | ០ | ១ | ១៥៩ |
| ថ្ងៃទី៤ | ២៥២ | ១២៩ | ១៣ | ៦ | ៣៨១ |
| ថ្ងៃទី៥ | ២៧៤ | ៩៩ | ១៥ | ១២ | ៣៧៣ |
| ថ្ងៃទី៦ | ២៩៣ | ៧០ | ១៥ | ២២ | ៣៦៣ |
| ថ្ងៃទី៧ | ២៩៨ | ៦៥ | ១៥ | ២២ | ៣៦៣ |

**អត្រាដំណុះ (%)**

$$\frac{\text{គ្រាប់ពូជដុះសរុប}}{\text{គ្រាប់ពូជសំណាក (៤០០)}} \times \text{១០០}$$

ថ្ងៃទី៣: $$\frac{\text{១៥៩}}{\text{៤០០}} \times \text{១០០} = \text{៣៩,៧៥}\%$$

ថ្ងៃទី៧: $$\frac{\text{៣៦៣}}{\text{៤០០}} \times \text{១០០} = \text{៩០,៧៥}\%$$

* គ្រាប់ដុះដែលរងការបំផ្លាញដោយសារផ្សិត ឬងាប់ មិនត្រូវរាប់បញ្ចូលជាគ្រាប់ពូជដុះទេ។

**ដំណេកគ្រាប់ពូជ៖**

ជាទូទៅ គ្រាប់ពូជស្រូវមិនអាចដុះលូតលាស់ភ្លាមៗបន្ទាប់ពីប្រមូលផលរួច។ រយៈពេលដំណេកគ្រាប់ពូជអាស្រ័យទៅតាមប្រភេទពូជនីមួយៗ។ ជាធម្មតា រយៈពេលដំណេកគ្រាប់ពូជនៃប្រភេទពូជនីមួយៗ ដែលត្រូវបានដាំដុះក្នុងប្រទេសកម្ពុជា គឺថិតក្នុងរង្វង់២១(ម្ភៃមួយ)ថ្ងៃ ប៉ុន្តែពូជក្នុងស្រុកខ្លះអាចមានដំណេកគ្រាប់ពី១(មួយ)ខែទៅ៣(បី)ខែ។ ប្រសិនបើអត្រាដំណុះទាបពេក ត្រូវវិភាគដំណុះគ្រាប់ពូជម្តងទៀត បន្ទាប់ពី៣-៤សប្តាហ៍ក្រោយមក។

# ឧបសម្ព័ន្ធទី១

# ឯកសារ និងឧទ្រម្ធ់របាយការណ៍ផ្សេងៗ

1-A. **ពាក្យស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ**

ឈ្មោះអ្នកស្នើសុំ៖ ........................................................................................ ភេទ៖ .....................

ឈ្មោះអង្គភាព/គ្រឹះស្ថាន៖.................................................តួនាទី៖ .................................................

អាសយដ្ឋាន៖ ភូមិ............ឃុំ/សង្កាត់...............ស្រុក/ខណ្ឌ..................ខេត្ត/រាជធានី.......................

លេខទូរស័ព្ទ៖ (ទី១).....................................................(ទី២).................................................

អ៊ីម៉ែល៖............................................................. តេឡេក្រាម៖..................................................

ឈ្មោះអ្នកទទួលខុសត្រូវចំពោះផលិតកម្មគ្រាប់ពូជ៖ ..........................................................................

ចំនួនសមាជិកចូលរួមនៅក្នុងផលិតកម្មគ្រាប់ពូជ៖............................នាក់ ក្នុងនោះស្ត្រីមាន៖...........នាក់

**១.ការបណ្តុះបណ្តាល**

វគ្គបណ្តុះបណ្តាលស្តីពីផលិតកម្មគ្រាប់ពូជ (✓)៖ ធ្លាប់បានទទួល ☐ មិនធ្លាប់បានទទួល ☐

| លរ. | អង្គភាពផ្តល់វគ្គបណ្តុះបណ្តាល | ឆ្នាំ | ចំនួនសមាជិក |
|---|---|---|---|
| ១ | | | |
| ២ | | | |
| ៣ | | | |
| ៤ | | | |
| ៥ | | | |

២. បទពិសោធន៍

ចំនួនឆ្នាំនៃបទពិសោធន៍ក្នុងផលិតកម្មគ្រាប់ពូជស្រូវ (ដូចមានឯកសារជូនភ្ជាប់មកជាមួយ)៖....................

ប្រភេទគ្រាប់ពូជស្រូវដែលសមាជិកក្រុមធ្លាប់ផលិត៖..........................................................................

៣. ប្រវត្តិនៃការផលិតគ្រាប់ពូជស្រូវ

ផ្ទៃដីនិងបរិមាណគ្រាប់ពូជបានផលិតក្នុងរយៈពេលបីឆ្នាំចុងក្រោយ៖

| ឈ្មោះពូជ | ឆ្នាំ២០......... | | ឆ្នាំ២០......... | | ឆ្នាំ២០......... | |
|---|---|---|---|---|---|---|
| | ហ.ត | តោន | ហ.ត | តោន | ហ.ត | តោន |
| ១. | | | | | | |
| ២. | | | | | | |
| ៣. | | | | | | |
| ៤. | | | | | | |
| ៥. | | | | | | |
| សរុប | | | | | | |

## ៤. គ្រឿងបរិក្ខារ

មានឬអាចរកជួលបានសម្រាប់ផលិតកម្មគ្រាប់ពូជ៖

| គ្រឿងបរិក្ខា | ផ្ទាល់ខ្លួន (✓) | ជួលគេ (✓) | កំណត់សម្គាល់ |
|---|---|---|---|
| ត្រាក់ទ័រ | | | |
| គោយន្ត | | | |
| នង្គ័ល | | | |
| ម៉ាស៊ីនវាយដី (រ៉ូតាវ៉ាទ័រ) | | | |
| ម៉ាស៊ីនស្ទូង | | | |
| ឧបករណ៍/ម៉ាស៊ីនដាំគ្រាប់ពូជជាជួរ | | | |
| ឧបករណ៍/ម៉ាស៊ីនបាញ់ថ្នាំ | | | |
| សម្ភារការពារខ្លួន | | | |
| ម៉ាស៊ីនច្រូត | | | |
| ឡសម្ងួត (សូមបញ្ជាក់ប្រភេទ) | | | |
| ម៉ាស៊ីនសម្អាតគ្រាប់ពូជ | | | |
| ម៉ាស៊ីនបក់គ្រាប់ពូជ | | | |
| ជញ្ជីង | | | |
| កំណាល់(ប៉ាឡែត) | | | |
| រទេះរុញ | | | |
| ឧបករណ៍វាស់សំណើម | | | |
| ឃ្លាំងសម្រាប់រក្សាគ្រាប់ពូជ | ...............ម² | ...............ម² | សរុប៖................................ ម² |
| ផ្សេងទៀត (សូមបញ្ជាក់) | | | |

## ៥. ផែនការផលិតកម្មគ្រាប់ពូជស្រូវសរុបសម្រាប់៣ឆ្នាំ៖..........................................(ហ.ត)

| ទីតាំង ផលិតកម្ម | ឆ្នាំ២០............................ | | | ឆ្នាំ២០............................ | | | ឆ្នាំ ២០............................ | | |
|---|---|---|---|---|---|---|---|---|---|
| | ដើមរដូវវស្សា | រដូវវស្សា | រដូវប្រាំង | ដើមរដូវវស្សា | រដូវវស្សា | រដូវប្រាំង | ដើមរដូវវស្សា | រដូវវស្សា | រដូវប្រាំង |
| ១. | | | | | | | | | |
| ២. | | | | | | | | | |
| ៣. | | | | | | | | | |
| ៤. | | | | | | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៥. | | | | | | | | | |
| សរុប | | | | | | | | | |

**៦. ឯកសារជូនភ្ជាប់៖**

ក. វិញ្ញាបនបត្រវគ្គបណ្តុះបណ្តាលផលិតកម្មគ្រាប់ពូជស្រូវ ☐

ខ. កិច្ចសន្យាផលិតកម្មកន្លងមក (ប្រសិនបើមាន) ☐

គ. រចនាសម្ព័ន្ធអាជីវកម្មគ្រាប់ពូជស្រូវ ☐

ខ្ញុំសូមធានាអះអាងចំពោះអង្គភាពមានសមត្ថកិច្ចថា រាល់ព័ត៌មានខាងលើពិតជាត្រឹមត្រូវ និងសូមសន្យាអនុវត្តផលិតកម្មគ្រាប់ពូជស្រូវតាមគោលការណ៍ប្រព័ន្ធធានាគុណភាពពូជដំណាំ **(ប.គ.ព)**។

ធ្វើនៅ .......................ថ្ងៃទី ................/.........../...........

ហត្ថលេខានិងឈ្មោះអ្នកស្នើសុំ៖

.................................................................

1-B. **គម្រូលិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គនាយកដ្ឋានកសិកម្ម**

លេខ៖............................................អ.ន.ក

**លិខិតអនុញ្ញាត**
**ធ្វើអាជីវកម្មផលិត កែច្នៃពូជដំណាំ**

**អគ្គនាយកដ្ឋានកសិកម្ម**

- បានឃើញព្រះរាជក្រម លេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
- បានឃើញប្រកាស លេខ**៣៧៥ ប្រក.កសក** ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីគំរូពាក្យស្នើសុំនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ
- បានឃើញពាក្យស្នើសុំលេខ...........................................ចុះថ្ងៃទី..................ខែ................ឆ្នាំ២០..............

**សម្រេច**

**អនុញ្ញាតឱ្យ៖** លោក/លោកស្រី ...............................................................................មុខងារ...............................................................................................
ក្រុមហ៊ុនឬនីតិបុគ្គល.......................................................................................................................................................................................
**ធ្វើអាជីវកម្មផលិតកែច្នៃពូជដំណាំ**. ..............................................................ដែលមានសមត្ថភាពផលិតកែច្នៃពូជដំណាំប្រចាំឆ្នាំ...................................................
អាសយដ្ឋានរបស់គ្រឹះស្ថាន.................................................................................................................................................................................

**សុពលភាព៖** លិខិតអនុញ្ញាតនេះត្រូវបានប្រគល់ជូនសាមីអ្នកស្នើសុំ ដើម្បីប្រើប្រាស់ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំជាធរមានក្នុងសុពលភាពរយៈពេល **៣ឆ្នាំ** ដោយគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតនេះ និងត្រូវផុតសុពលភាពនៅថ្ងៃទី................ខែ...........ឆ្នាំ២០.....លើកលែងតែមានការដកហូតដោយអគ្គនាយកដ្ឋានកសិកម្មនៅមុនកាលបរិច្ឆេទផុតសុពលភាព។

រាជធានីភ្នំពេញ ថ្ងៃទី.................ខែ.............ឆ្នាំ២០........

**អគ្គនាយក**

## 1-C. ទម្រង់(ក)៖ ផែនការផលិតកម្មគ្រាប់ពូជស្រូវប្រចាំរដូវ

១. ឈ្មោះអ្នកស្នើសុំ៖..........................................................................................ភេទ៖.................

២. ឈ្មោះស្ថាប័ន៖..........................................................................................តួនាទី៖..........................

៣. អាសយដ្ឋាន៖ ភូមិ.............ឃុំ/សង្កាត់..................ស្រុក/ខណ្ឌ.................ខេត្ត/រាជធានី.................

៤. លេខទូរស័ព្ទ៖ (ទី១).................................................(ទី២).....................................................

៥. អ៊ីម៉ែល៖...........................................................តេឡេក្រាម៖.................................................

៦. លេខលិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ...................................ចុះថ្ងៃទី............/............./.......

៧. រដូវដាំដុះ៖.................កាលបរិច្ឆេទចាប់ផ្តើមដាំដុះ៖....................កាលបរិច្ឆេទគ្រោងប្រមូលផល៖.....

៨. ព័ត៌មានស្តីពីផលិតកម្មគ្រាប់ពូជ៖

| ល.រ. | ឈ្មោះពូជ | ថ្នាក់គ្រាប់ពូជ | ផ្ទៃដី(ត.ហ) | ចំនួនស្រែ | ទីតាំងផលិតកម្ម |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| | សរុប | | | | |

៩. ព័ត៌មានស្តីពីប្រភពគ្រាប់ពូជប្រើប្រាស់ក្នុងផលិតកម្មគ្រាប់ពូជ

| ល.រ. | ឈ្មោះពូជ | ថ្នាក់គ្រាប់ពូជ | បរិមាណ(គ្រ.គ) | លេខឡូតិ៍ |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ៤ | | | | |
| ៥ | | | | |
| | សរុប | | | |

**កំណត់សម្គាល់៖ អ្នកផលិតគ្រាប់ពូជត្រូវរក្សាទុករាល់ស្លាកសំណៅដើម បាវវេចខ្ចប់ វិក្កយបត្រទិញគ្រាប់ពូជសម្រាប់ផ្ទៀងផ្ទាត់ដោយស្ថាប័នមានសមត្ថកិច្ច។*

១០. ឯកសារជូនភ្ជាប់ (សូមមើលតារាងគំរូ)

ខ្ញុំសូមធានាអះអាងចំពោះអង្គភាពមានសមត្ថកិច្ចថា រាល់ព័ត៌មានខាងលើពិតជាត្រឹមត្រូវ។ ក្នុងករណីស្រែផលិតកម្មគ្រាប់ពូជខូចខាត ឬប្រែប្រួលដោយប្រការណាមួយ ខ្ញុំនឹងជូនដំណឹងទៅអង្គភាពមានសមត្ថកិច្ច។

ធ្វើនៅ.......................ថ្ងៃទី.........../........../................

ហត្ថលេខានិងឈ្មោះអ្នកស្នើសុំ៖

..................................................................

## គម្រូឯកសារជូនភ្ជាប់៖ បញ្ជីឈ្មោះសមាជិកក្រុមផលិតគ្រាប់ពូជស្រូវ

| លរ. | ឈ្មោះ | ភេទ | កូដ<br>អ្នកផលិត | ពូជ<br>ផលិត | ថ្នាក់<br>គ្រាប់ពូជ | ផ្ទៃដីផលិត<br>(ត.ហ) | ចំនួន<br>ស្រែ | ផ្ទៃដីស្រែ<br>នីមួយៗ | កូដស្រែ |
|---|---|---|---|---|---|---|---|---|---|
| ១ | អ៊ឹម សេរី | ប | G001 | PRD | CS | 1.2 | 2 | 0.7 | G001F01 |
| | | | | | | | | 0.5 | G001F02 |
| ២ | លឹម លាភ | ស | G002 | SKO | CS | 2.2 | 2 | 1.2 | G002F01 |
| | | | | | | | | 1.0 | G002F02 |

## 1-D. ទម្រង់កំណត់ត្រាត្រួតពិនិត្យគុណភាពទីវាល

**ប្រើសម្រាប់តែកត់ត្រាប៉ុណ្ណោះ**

ឈ្មោះម្ចាស់ស្រែ៖ ____________________ កាលបរិច្ឆេទ៖ ____________________

លេខពាក្យស្នើសុំ៖ កូដស្រែ៖

| ឈ្មោះពូជ | កាលបរិច្ឆេទ ដាំដុះ | កាលបរិច្ឆេទ ត្រួតពិនិត្យគុណភាព ទីវាលលើកទី១ | កាលបរិច្ឆេទ រំពឹងទុកនៅ ដំណាក់កាលចេញផ្កា | កាលបរិច្ឆេទ ត្រួតពិនិត្យគុណភាព ទីវាលលើកទី២ | កាលបរិច្ឆេទ រំពឹងទុកនៅ ដំណាក់កាលច្រូត |
|---|---|---|---|---|---|
| | | | | | |

| ចំនួនសំណាក | ពូជលាយ | ស្មៅហាម ឃាត់ | ជំងឺហាមឃាត់ | | |
|---|---|---|---|---|---|
| | | | ប្លាស់ | អុចត្នោត | រលាកស្រទបស្លឹក |
| សំណាកទី ១ | | | ០ ១ ២ ៣ | ០ ១ ២ ៣ | ០ ១ ២ ៣ |
| សំណាកទី ២ | | | ០ ១ ២ ៣ | ០ ១ ២ ៣ | ០ ១ ២ ៣ |
| សំណាកទី ៣ | | | ០ ១ ២ ៣ | ០ ១ ២ ៣ | ០ ១ ២ ៣ |
| សំណាកទី ៤ | | | ០ ១ ២ ៣ | ០ ១ ២ ៣ | ០ ១ ២ ៣ |
| សំណាកទី ៥ | | | ០ ១ ២ ៣ | ០ ១ ២ ៣ | ០ ១ ២ ៣ |
| សំណាកទី ៦ | | | ០ ១ ២ ៣ | ០ ១ ២ ៣ | ០ ១ ២ ៣ |
| សំណាកទី ៧ | | | ០ ១ ២ ៣ | ០ ១ ២ ៣ | ០ ១ ២ ៣ |
| សំណាកទី ៨ | | | ០ ១ ២ ៣ | ០ ១ ២ ៣ | ០ ១ ២ ៣ |
| សំណាកទី ៩ | | | ០ ១ ២ ៣ | ០ ១ ២ ៣ | ០ ១ ២ ៣ |
| សំណាកទី ១០ | | | ០ ១ ២ ៣ | ០ ១ ២ ៣ | ០ ១ ២ ៣ |
| **សរុប** | | | ០ ១ ២ ៣ | ០ ១ ២ ៣ | ០ ១ ២ ៣ |
| | ▼ | ▼ | | ▼ | |
| ១០ម$^2$ | | | វិនិច្ឆ័យជំងឺជារួម | | ០ ១ ២ ៣ |

**<u>សម្គាល់៖</u>** ០-ស្រូវគ្មានជំងឺ, ១-ស្រូវមានជំងឺតិចជាង២៥%, ២-ស្រូវមានជំងឺតិចជាង៥០%, និង៣-ស្រូវមានជំងឺលើស៥០%។

1-E. **ទម្រង់របាយការណ៍ត្រួតពិនិត្យគុណភាពផលិតកម្មទីវាល**

លេខកូដស្រែ.................................................... លេខរបាយការណ៍............................................

កាលបរិច្ឆេទត្រួតពិនិត្យ................../.........../.......... ពេលវេលាះពីម៉ោង..............ដល់ម៉ោង..............

ឈ្មោះពូជស្រូវ..................................................... ថ្នាក់គ្រាប់ពូជ.................................................

កាលបរិច្ឆេទដាំ/ស្ទូង..................../.........../............ កាលបរិច្ឆេទគ្រោងប្រមូលផល........./......../.........

១.ឈ្មោះអ្នកផលិត................................................ លេខកូដអ្នកផលិត...........................................

២. អាសយដ្ឋាន៖ ភូមិ.................ឃុំ/សង្កាត់...............ស្រុក/ខណ្ឌ............ខេត្ត/រាជធានី...................

៣. ទីតាំងស្រែ.....................................................................................................................

៤. ប្រភពគ្រាប់ពូជ...................................................កាលបរិច្ឆេទទិញ..........................................

៥. ផ្ទៃដីផលិតកម្មគ្រាប់ពូជសរុបនៃពូជស្រូវខាងលើ...............................................................ហិចតា

៦. ផ្ទៃដីស្រែត្រូវត្រួតពិនិត្យ.....................................................................................................ហិចតា

៧. ប្រភេទដំណាំបានដាំពីមុននៅក្នុងស្រែ.......................................គម្លាតពីស្រែជុំវិញ.......................

៨. ដំណាក់កាលស្រូវពូជខាងលើនៅពេលត្រួតពិនិត្យ.........................................................................

៩. លទ្ធផលតាមសំណាក (អនុវត្តតាមគោលការណែនាំ)

| លេខរៀងសំណាក | ☐ ចំនួនដើម(លើកទី១) ☐ ចំនួនកួរ(លើកទី២) | | ភាគរយ |
|---|---|---|---|
| | ពូជលាយ | ស្មៅហាមឃាត់ | ជំងឺហាមឃាត់ |
| ១. | | | |
| ២. | | | |
| ៣. | | | |
| ៤. | | | |
| ៥. | | | |
| ៦. | | | |
| ៧. | | | |
| ៨. | | | |
| ៩. | | | |
| ១០. | | | |
| សរុប | | | |

១០. (ក) ឈ្មោះជំងឺហាមឃាត់៖ ☐ ប្លាស់ ☐ អុចត្នោត ☐ រលាកស្រទបស្លឹក

(ខ) ប្រភេទស្មៅហាមឃាត់.....................................................................................................

១១. ស្ថានភាពលូតលាស់របស់ដំណាំស្រូវ.........................................................................................

១២. តើដំណាំស្រូវនេះអនុលោមទៅតាមស្តង់ដារទីវាលដែរទេ?...........................................................

១៣. គុណភាពនៃការងារផលិតកម្មគ្រាប់ពូជ.........................................................................................

១៤. តើនេះជារបាយការណ៍ចុងក្រោយមែនទេ ?..........................................................................................

១៥. ទិន្នផលគ្រាប់ពូជស្រូវត្រូវបានប៉ាន់ប្រមាណ ( តោន/ហិចតា )...............................................................

១៦. តើអ្នកផលិតឬតំណាងរបស់គាត់មានវត្តមានក្នុងពេលត្រួតពិនិត្យដែរឬទេ ?.....................................

១៧. អនុសាសន៍/សេចក្តីសន្និដ្ឋាន/កំណត់សំគាល់.....................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

ហត្ថលេខាអ្នកផលិត | ហត្ថលេខាមន្ត្រីត្រួតពិនិត្យ

ឈ្មោះ | ឈ្មោះ

1-F. **ទម្រង់(ខ)៖ សំណើសុំត្រួតពិនិត្យគុណភាពគ្រាប់ពូជ**

១. ឈ្មោះអ្នកស្នើសុំ៖...............................ភេទ៖...............តួនាទី៖.............................................

២. អាសយដ្ឋាន៖ ភូមិ..........ឃុំ/សង្កាត់..................ស្រុក/ខណ្ឌ.................ខេត្ត/រាជធានី..................

៣. លេខទូរស័ព្ទ៖ (ទី១).............................................(ទី២)..................................................

៤. អ៊ីម៉ែល៖.........................................................តេឡេក្រាម៖..................................................

៥. លេខលិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ.................................ចុះថ្ងៃទី......../............/.............

៦. ជម្រើសនៃការត្រួតពិនិត្យគុណភាព (សូមគូសយកតែមួយប៉ុណ្ណោះ)៖

ក. ១០%នៃឡូត៍គ្រាប់ពូជសរុបនៃពូជនីមួយៗ ☐

ខ. គ្រប់ឡូត៍គ្រាប់ពូជទាំងអស់ ☐

| លរ. | ឡូត៍គ្រាប់ពូជ | បរិមាណ (គ្រ.គ) | ឈ្មោះពូជ | ថ្នាក់គ្រាប់ពូជ | ចំនួនបាវសម្រាប់ផ្តល់ស្លាកសញ្ញាបញ្ជាក់ គុណភាព បព.គ. |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| សរុប | | | | | |

*❋កំណត់សម្គាល់៖ ក្នុងករណីឡូត៍គ្រាប់ពូជមានចំនួនច្រើន សូមភ្ជាប់បន្ថែមតាមតារាងគំរូខាងលើ។*

៧. គ្រាប់ពូជត្រូវបានដាក់ថ្នាំខ្ទូតនៅថ្ងៃទី.............ខែ...........ឆ្នាំ................ដោយប្រើថ្នាំឈ្មោះ................ បានរយៈពេល.....................ម៉ោង ឬ................ថ្ងៃ។

ខ្ញុំសូមធានាអះអាងថា គ្រាប់ពូជនៃឡូត៍នីមួយៗត្រូវបានផលិតស្របតាមលក្ខខណ្ឌតម្រូវនៃប្រព័ន្ធធានាគុណភាពពូជដំណាំ (ប.គ.ព)។

ខ្ញុំសូមគោរពអញ្ជើញមន្ត្រីមានសមត្ថកិច្ចចុះមកត្រួតពិនិត្យគុណភាពគ្រាប់ពូជដោយក្តីអនុគ្រោះ។

ធ្វើនៅ..........................ថ្ងៃទី........../.............../...........

ហត្ថលេខានិងឈ្មោះអ្នកស្នើសុំ៖

..................................................................

1-G. **ទម្រង់កត់ត្រាវិភាគដំណុះ**

ប្រើសម្រាប់តែកត់ត្រាប៉ុណ្ណោះ

ឈ្មោះអ្នកផលិត៖ ........................................................................ កូដអ្នកផលិត៖ ........................................

លេខសំណាក៖ ..........................................................................................................................................

| ថ្ងៃ | កាលបរិច្ឆេទ (ថ្ងៃ/ខែ/ឆ្នាំ) | គ្រាប់ដុះធម្មតា (A) | គ្រាប់ដុះខ្សោយ (B) | គ្រាប់រឹង (C) | គ្រាប់ខូច ឬងាប់ (D) * | សរុបដំណុះ (A)+(B) |
|---|---|---|---|---|---|---|
| ថ្ងៃទី១ | | | | | | |
| ថ្ងៃទី២ | | | | | | |
| ថ្ងៃទី៣ | | | | | | |
| ថ្ងៃទី៤ | | | | | | |
| ថ្ងៃទី៥ | | | | | | |
| ថ្ងៃទី៦ | | | | | | |
| ថ្ងៃទី៧ | | | | | | |

* គ្រាប់ដែលដុះហើយខូច ឬងាប់មិនគួររាប់បញ្ចូលទៅក្នុងដំណុះសរុបនោះទេ។

អត្រាដំណុះនៅថ្ងៃទី៣

គ្រាប់ដុះសរុប [ ]

គ្រាប់ធ្វើតេស្តសរុប ៤00

= [ ] %

អត្រាដំណុះនៅថ្ងៃទី៧

គ្រាប់ដុះសរុប [ ]

គ្រាប់ធ្វើតេស្តសរុប ៤00

= [ ] %

## 1-H. ទម្រង់របាយការណ៍ត្រួតពិនិត្យគុណភាពគ្រាប់ពូជ

លេខរបាយការណ៍៖ ..................................................

### ១. ព័ត៌មាននៃអ្នកស្នើសុំ

- ឈ្មោះអ្នកផលិត៖ ............................................................ កូដអ្នកផលិត៖ ......................
- កាលបរិច្ឆេទនៃការបញ្ជូនសំណាក៖ ............./ ............./.......................................................

### ២. កាលបរិច្ឆេទ និងទីតាំងនៃការត្រួតពិនិត្យគុណភាព

- តេស្តិ៍ភាពសុទ្ធ៖ .........../ .........../.................. តេស្តិ៍សំណើម៖ .........../ .........../.....................
- តេស្តិ៍ដំណុះ៖ ពីថ្ងៃទី ........../ ........../............. ដល់ថ្ងៃទី ......../ ........../............ (សរុប....... ថ្ងៃ)
- ទីតាំងត្រួតពិនិត្យ៖ ...................................................................................................
- ឈ្មោះមន្ត្រីត្រួតពិនិត្យ៖ .......................................... អង្គភាព៖ .........................................

### ៣. ព័ត៌មានសំណាកយកមកត្រួតពិនិត្យ

- ដំណាំ៖ ................ ឈ្មោះពូជ៖ ............................................. ថ្នាក់គ្រាប់ពូជ៖ RS / CS
- ឡូតិ៍គ្រាប់ពូជរបស់អ្នកផលិត៖ ...........................................................................................
- កាលបរិច្ឆេទប្រមូលផល៖ .........../ .........../................ បរិមាណសំណាក៖ ..................... ក្រាម

### ៤. លទ្ធផលត្រួតពិនិត្យគុណភាពគ្រាប់ពូជស្រូវ

<table>
<tr><th rowspan="2" colspan="2">កត្តា</th><th rowspan="2">តួលេខធ្វើតេស្តិ៍</th><th colspan="2">ស្តង់ដារ</th><th rowspan="2">លទ្ធផល ជាប់/ធ្លាក់</th></tr>
<tr><th>RS</th><th>CS</th></tr>
<tr><td colspan="2">1. គ្រាប់ពូជសុទ្ធ (អប្បបរមា, %)</td><td></td><td>៩៨</td><td>៩៨</td><td>ជាប់/ធ្លាក់</td></tr>
<tr><td colspan="2">2. កម្ទេចកម្ទី (អតិបរមា, %)</td><td></td><td>២</td><td>២</td><td>ជាប់/ធ្លាក់</td></tr>
<tr><td colspan="2">គ្រាប់ពូជស្មៅ (អតិបរមា, ចំនួនគ្រាប់/៥០០ក្រាម)</td><td></td><td>៥</td><td>១០</td><td>ជាប់/ធ្លាក់</td></tr>
<tr><td colspan="2">គ្រាប់ពូជដំណាំផ្សេង (អតិបរមា, ចំនួនគ្រាប់/៥០០ក្រាម)</td><td></td><td>៣</td><td>៥</td><td>ជាប់/ធ្លាក់</td></tr>
<tr><td colspan="2">គ្រាប់ពូជស្រូវផ្សេង (អតិបរមា, ចំនួនគ្រាប់/៥០០ក្រាម)</td><td></td><td>៥</td><td>១៥</td><td>ជាប់/ធ្លាក់</td></tr>
<tr><td colspan="2">ស្រូវក្រហម (អតិបរមា, ចំនួនគ្រាប់/៥០០ក្រាម)</td><td></td><td>២</td><td>៥</td><td>ជាប់/ធ្លាក់</td></tr>
<tr><td rowspan="2">3. អត្រាដំណុះ (អប្បបរមា, %)</td><td>៣ ថ្ងៃ</td><td></td><td>-</td><td>-</td><td>-</td></tr>
<tr><td>៧ ថ្ងៃ</td><td></td><td>៨៥</td><td>៨០</td><td>ជាប់/ធ្លាក់</td></tr>
<tr><td colspan="2">4. សំណើមគ្រាប់ពូជ (អតិបរមា, %)</td><td></td><td>១៣</td><td>១៤</td><td>ជាប់/ធ្លាក់</td></tr>
</table>

៥. កំណត់សំគាល់/សន្និដ្ឋានៈ

.................................................................................................................................................
.................................................................................................................................................
.................................................................................................................................................
.................................................................................................................................................

ធ្វើនៅ......................., ថ្ងៃទី............../........../..............

ហត្ថលេខានិងឈ្មោះមន្ត្រីត្រួតពិនិត្យ

.................................................................

# ឧបសម្ព័ន្ធទី២

## ឧបករណ៍ និងសម្ភារសម្រាប់ត្រួតពិនិត្យគុណភាព

## ១. ឧបករណ៍សម្រាប់ត្រួតពិនិត្យគុណភាពទីវាល

| | |
|---|---|
| **ម៉ែត្រវាស់ (ប្រវែងជាង 3ម)**<br><br>ដើម្បីពិនិត្យមើលគម្លាតស្រែ ប្រើសម្រាប់វាស់និងពិនិត្យចម្ងាយរវាងស្រែផលិតកម្មនិងស្រែស្រូវផ្សេងទៀតឱ្យបានត្រឹមត្រូវ |  |
| **ស៊ុម១ម៉ែត្របួនជ្រុង (១ម x ១ម)**<br><br>ដើម្បីកំណត់កន្លែងយកសំណាកសម្រាប់ត្រួតពិនិត្យគុណភាព ត្រូវប្រើស៊ុម១ម៉ែត្របួនជ្រុង។ វាអាចធ្វើវាពីបំពង់ជ័រ PVC និងស៊កបញ្ចូលគ្នា ដែលអាចរកទិញបាននៅទីផ្សារ |  |
| **ក្តារទ្រនាប់កត់ត្រា**<br><br>វាមានប្រយោជន៍សម្រាប់កត់ត្រាលទ្ធផលត្រួតពិនិត្យគុណភាពផលិតកម្មទីវាល |  |
| **ឯកសណ្ឋានសមរម្យសម្រាប់ប្រតិបត្តិការការងារនៅទីវាល**<br><br>អ្នកផលិតគ្រាប់ពូជអាចទើបតែបាញ់ថ្នាំកសិកម្មក្នុងស្រែរបស់គាត់។ ដូច្នេះត្រូវពាក់ឯកសណ្ឋានសមស្របដើម្បីការងារខ្លួនរបស់អ្នក។ |  |

## ២. ឧបករណ៍សម្រាប់យកសំណាក

| | |
|---|---|
| **ដែកឆាំគ្រាប់ពូជ**<br><br>ដើម្បីបញ្ចៀសការខូចបាវវេចខ្ចប់ ត្រូវប្រើដែកឆាំគ្រាប់ពូជ។ ស៊កដែកឆាំចូលទៅក្នុងបាវវេចខ្ចប់ រួចបង្វិលវាថ្នមៗដើម្បីទាញយកសំណាក |  |
| **ថង់ប្លាស្ទិច**<br><br>ដើម្បីបញ្ចៀសការលាយឡំសំណាក ត្រូវប្រើថង់ប្លាស្ទីកដើម្បីរក្សាទុកសំណាក។ សំណាកគួរតែស្ងួតល្អមមុននឹងដាក់វាចូលទៅក្នុងថង់ |  |
| **បិទស្លាកសំគាល់លើសំណាក**<br><br>បន្ទាប់ពីច្រកសំណាកចូលក្នុងថង់ប្លាស្ទិចរួច ត្រូវបិទស្លាកសំគាល់លើវាភ្ជាមជាមួយនឹងព័ត៌មានចាំបាច់ ដើម្បីបញ្ចៀសការច្រឡំសំណាក។ |  |

## ៣. ឧបករណ៍ និងសម្ភារសម្រាប់វិភាគគុណភាពនៅមន្ទីរពិសោធន៍

| | |
|---|---|
| **ជញ្ជីងអេឡិចត្រូនិច**<br>ភាគរយនៃភាពសុទ្ធត្រូវបានគណនាដោយផ្អែកលើទម្ងន់។ ដូច្នេះ ទម្ងន់នៃសំណាកគួរតែថ្លឹងឱ្យបានត្រឹមត្រូវ។ ជញ្ជីងអេឡិចត្រូនិចជាឧបករណ៍ទំនើប ហើយត្រូវបំផ្លាស់ទីដោយប្រុងប្រយ័ត្ន |  |
| **បន្ទះក្តារសម្រាប់ពិនិត្យភាពសុទ្ធគ្រាប់ពូជ**<br>ដើម្បីកំណត់ស្រូវក្រហម ប្រើបន្ទះក្តារសម្រាប់ពិនិត្យគ្រាប់ពូជមានបញ្ចាំងពន្លឺ ដោយប្រើចរន្តអគ្គីសនីសម្រាប់ដំណើការឧបករណ៍នេះ |  |
| **បន្ទះឈើ**<br>ដើម្បីបញ្ចៀសការឆ្កូតផ្ទៃមុខលើនៃបន្ទះក្តារវិភាគគ្រាប់ពូជ ត្រូវប្រើបន្ទះឈើសម្រាប់ត្រួតពិនិត្យសំណាកនៅលើបន្ទះក្តារវិភាគ |  |
| **ឧបករណ៍វាស់សំណើម**<br>ដើម្បីពិនិត្យសំណើមសំណាកត្រូវប្រើឧបករណ៍វាស់សំណើមអេឡិចត្រូនិច |  |
| **ប្រអប់បណ្តុះសាក**<br>ប្រអប់ប្លាស្ទិចណាក៏បានដែលគេអាចយកមកប្រើសម្រាប់វិភាគដំណុះ |  |

| | |
|---|---|
| **ក្រដាសសម្រាប់វិភាគដំណុះ**<br><br>ក្រដាសគួរតែដាក់ទ្រាប់បាតក្រោមនៃប្រអប់ដំណុះ ដើម្បីរក្សាគ្រាប់ឱ្យនៅសើមក្នុងពេលវិភាគដំណុះ។ ក្រដាសអនាម័យ ឬក្រដាសជូតមាត់អាចប្រើប្រាស់បាន |  |
| **ដង្កៀបចាប់**<br><br>ប្រើដង្កៀបចាប់ដើម្បីតម្រៀបគ្រាប់ពូជជាជួរនៅក្នុងប្រអប់បណ្ដុះសាក ដូច្នេះយើងអាចសង្កេតនិងរាប់គ្រាប់ពូជងាយស្រួល |  |
| **ដបបាញ់ទឹក**<br><br>ដើម្បីរក្សាសំណើមគ្រាប់ពូជក្នុងការវិភាគដំណុះគ្រាប់ពូជ ត្រូវបាញ់ទឹកពីម្ដងទៅម្ដងដោយប្រើដបបាញ់ទឹក |  |

# ឧបសម្ព័ន្ធទី៣
# សន្ទានុក្រម

**ប្រព័ន្ធធានាគុណភាពពូជដំណាំ (ព.គ.ប) (Quality Declared Seed-QDS System)**

ប្រព័ន្ធធានាគុណភាពពូជដំណាំ ដែលសរសេរអក្សរកាត់ **ប.គ.ព** ជាប្រព័ន្ធធានាការបញ្ជាក់គុណភាពពូជដំណាំគ្រប់ប្រភេទដែលបានចុះបញ្ជីស្របច្បាប់ នៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ផលិតកម្មពូជដំណាំនៅក្នុងស្រុក ធ្វើអាជីវកម្ម ឬការធ្វើចរាចរណ៍លើទីផ្សារនៅក្នុងប្រទេសឬការធ្វើពាណិជ្ជកម្មក្រៅប្រទេស។

**អង្គភាពមានសមត្ថកិច្ច (Competency authority-CA)**

សំដៅលើ**នាយកដ្ឋានពូជដំណាំ**នៃអគ្គនាយកដ្ឋានកសិកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទរាជធានី ខេត្ត គឺជាអង្គភាពមានសមត្ថកិច្ច(CA)។

**មន្ត្រីទទួលបន្ទុក**

សំដៅលើមន្ត្រីទទួលបន្ទុកនៃ**នាយកដ្ឋានពូជដំណាំ**មានតួនាទីសំខាន់រៀបចំទុកដាក់ឯកសារពាក់ព័ន្ធទាំងអស់ដែលបានបញ្ជូនមក ព្រមទាំងកត់សម្គាល់ និងវាយតម្លៃអ្នកស្នើសុំជូន**អគ្គនាយកដ្ឋានកសិកម្ម** ដើម្បីធ្វើការសម្រេចចិត្តអនុញ្ញាតផ្តល់អនុសាសន៍កែតម្រូវ ឬបដិសេធផ្តល់ជូនលិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ និងផ្តល់ស្លាកសញ្ញាបញ្ជាក់គុណភាព **ប.គ.ព** ជូនអ្នកស្នើសុំ។

**អ្នកផលិតគ្រាប់ពូជ**

អ្នកផលិតគ្រាប់ពូជ គឺសំដៅដល់បុគ្គល ក្រុម ក្រុមហ៊ុន សហគមន៍កសិកម្ម ឬអង្គការក្រៅរដ្ឋាភិបាល ដែលផលិតនិងធ្វើអាជីវកម្មគ្រាប់ពូជ។ អ្នកផលិតគ្រាប់ពូជស្របច្បាប់នឹងត្រូវទទួលបានវិញ្ញាបនបត្រដែលបញ្ជាក់ថា ពួកគាត់មានសិទ្ធិផលិត និងធ្វើធុរកិច្ចគ្រាប់ពូជដែលអនុលោមទៅតាម **ប.គ.ព**។

**គ្រាប់ពូជគ្រឹះ (Foundation Seed - FS)**

សំដៅដល់ពូជដំណាំជំនាន់ក្រោយនៃពូជជម្រើសវិទូតាមវិធីសាស្ត្រស្ទូងជាជួរ មួយដើមក្នុងមួយដំណោត និងឋិតក្រោមការគ្រប់គ្រងផ្ទាល់របស់រុក្ខជម្រើសវិទូ ឬអ្នកផលិតគ្រាប់ពូជស្របច្បាប់។ ថ្នាក់គ្រាប់ពូជគ្រឹះត្រូវបានផលិតក្រោមវិធានទទួលស្គាល់ដោយអង្គភាពបញ្ជាក់គុណភាពពូជដំណាំក្នុងគោលបំណងរក្សាភាពសុទ្ធពន្ធុនិងអត្តសញ្ញាណរបស់ប្រភេទពូជតាមស្តង់ដារគុណភាពគ្រាប់ពូជ។

**គ្រាប់ពូជបញ្ជី (Registered Seed - RS)**

សំដៅដល់ពូជដំណាំដែលបានផលិតចេញពីគ្រាប់ពូជគ្រឹះ ដោយវិស័យសាធារណៈ ឬវិស័យឯកជនអ្នកផលិតគ្រាប់ពូជស្របច្បាប់សម្រាប់ធ្វើអាជីវកម្ម(វិធីសាស្ត្រដាំជាជួរ ឬស្ទូងជាជួរ ១-៣ដើមក្នុងមួយដំណោត)និងឋិតនៅក្រោមវិធានដែលទទួលស្គាល់ដោយអង្គភាពបញ្ជាក់គុណភាពពូជដំណាំ ដើម្បីរក្សាភាពសុទ្ធពន្ធុនិងអត្តសញ្ញាណរបស់ប្រភេទពូជតាមស្តង់ដារគុណភាពគ្រាប់ពូជ។

**គ្រាប់ពូជវិញ្ញាបនបត្រ (Certified Seed - CS)**

សំដៅដល់ពូជដំណាំដែលបានផលិតពីគ្រាប់ពូជចុះបញ្ជី ដោយអ្នកផលិតគ្រាប់ពូជ ឬស្ថានីយ៍អភិវឌ្ឍន៍សាធារណៈតាមវិធីសាស្ត្រដាំជាជួរ ឬស្ទូងធម្មតា១-៣ដើមក្នុងមួយដំណោត និងឋិតនៅក្រោមវិធានទទួលស្គាល់ដោយអង្គភាពបញ្ជាក់គុណភាពពូជដំណាំ ដើម្បីរក្សាភាពសុទ្ធពន្ធុនិងអត្តសញ្ញាណរបស់ប្រភេទពូជតាមស្តង់ដារគ្រាប់ពូជ។

**សំណាកបឋម**

សំណាកបឋមយកចេញពីបាវដែលបានជ្រើសរើសដោយចៃដន្យ និងមានបរិមាណប្រហាក់ប្រហែលគ្នា។ សំណាកបឋមត្រូវយកចេញពីផ្នែកខាងលើ ផ្នែកកណ្ដាល និងផ្នែកខាងក្រោមនៃបាវ ក្នុងករណីចំនួនបាវមានចន្លោះពី១ទៅ១៥។ ប្រសិនបើចំនួនបាវដែលត្រូវយកសំណាកបឋមលើសពី១៥បាវ មិនចាំបាច់យកសំណាកបឋមពី៣ទីតាំងក្នុងបាវតែមួយនោះទេ ប៉ុន្តែអាចយកចេញពី៣ទីតាំងផ្សេងគ្នានៃពំនូកបាវរបស់ឡូត៍គ្រាប់ពូជនីមួយៗ។

**សំណាករួម**

សំណាកបឋមត្រូវបានដាក់បញ្ចូលគ្នាទៅជាសំណាករួមតែមួយ នៅពេលសំណាកបឋមទាំងអស់នោះប្របល់ចូលគ្នាបានសព្វល្អ។

**សំណាកយោង**

សំណាកយោង ជាសំណាកសល់ពីសំណាករួម បន្ទាប់ពីដកយកសំណាកបញ្ជូនចេញរួចរាល់។ អ្នកផលិតត្រូវរក្សាសំណាកយោងទុកជាសំណាកបម្រុង និងសម្រាប់ធ្វើតេស្តគុណភាពផ្ទៃក្នុង។

**សំណាកបញ្ជូន**

សំណាកបញ្ជូនត្រូវបានយកចេញពីសំណាករួមសម្រាប់វិភាគនៅមន្ទីរពិសោធន៍។ ទម្ងន់សំណាកបញ្ជូនអប្បបរមាគឺ ៧០០ក្រាម។ ប្រសិនបើសំណាករួមមានបរិមាណជិត៧០០ក្រាម ត្រូវបញ្ជូនទៅមន្ទីរពិសោធន៍ទាំងអស់តែម្តង។ ប្រសិនបើសំណាករួមមានបរិមាណច្រើន នោះត្រូវរំលែកតាមវិធីរំលែកដោយដៃពាក់កណ្ដាលស្មើគ្នា ដើម្បីទទួលបានបរិមាណ ៧០០ក្រាម។

**សំណាកវិភាគ**

សំណាកវិភាគត្រូវបានយកចេញពីសំណាកបញ្ជូនតាមវិធីរំលែកដោយដៃពាក់កណ្ដាលស្មើគ្នា។ ទម្ងន់សំណាកវិភាគអប្បបរិមាគឺ៥០០ក្រាម។ សំណាកនេះប្រើសម្រាប់កំណត់រកភាពសុទ្ធ គ្រាប់ពូជដំណាំផ្សេង (គ្រាប់ពូជ ស្រូវផ្សេង ស្រូវក្រហម និងគ្រាប់ដំណាំផ្សេង) គ្រាប់ស្មៅ សំណើមគ្រាប់ពូជ កម្ទេចកម្ទីរផ្សេងទៀត និងដំណុះ គ្រាប់ពូជ។ ទម្ងន់២០០ក្រាមដែលនៅសល់ ត្រូវរក្សាទុកសម្រាប់ការធ្វើតេស្តសាឡើងវិញក្នុងករណីចាំបាច់។

**សមាគមវិភាគពូជដំណាំអន្តរជាតិ (International Seed Testing Association-ISTA) ឆ្នាំ 2018**

សមាគមវិភាគពូជដំណាំអន្តរជាតិ(ISTA) មានវិធានគោលការណ៍បច្ចេកទេសដែលត្រូវបានប្រើប្រាស់សម្រាប់យកសំណាក និងវិភាគគុណភាពគ្រាប់ពូជដំណាំ។